# សម្ភាសជាមួយឈ្មោះ សឿន វ៉ៃ ភេទប្រុស អាយុ៩៧ ឆ្នាំ

មុខងារខ្មែរក្រហមៈ អនុសេនាធំ

មុខងារបច្ចុប្បន្នៈ ធ្វើចំការ

មានស្រុកកំណើតនៅៈ ភូមិវត្តតាមឹម ឃុំវត្តតាមឹម ស្រុកបាត់ដំបង ខេត្តបាត់ដំបង

សព្វថ្ងៃរស់នៅភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០១:១៤:៣៩

២៩ ទំព័រ

ប៊ុនថន ៖ អញ្ជើញជំបូងខ្ញុំសុំអនុញ្ញាតសួរឈ្មោះលោកពូ ពូឈ្មោះអីដែរ?

វ៉ៃ ៖ ខ្ញុំឈ្មោះ សឿន វ៉ៃ ។

ប៊ុនថន ៖ ពូដល់សព្វថ្ងៃនេះអាយុប៉ុន្មានហើយ?

វ៉ៃ ៖ ខ្ញុំអាយុ៩៧ឆ្នាំ ។

ប៊ុនថន ៖ ពូមានស្រុកកំណើតនៅភូមិឃុំអីដែរលោកពូ?

វ៉ៃ ៖ ខ្ញុំស្រុកកំណើតនៅភូមិវត្តតាមឹម ឃុំវត្តតាមឹម ស្រុកបាត់ដំបង ។

ប៊ុនថន ៖ បាទ!បច្ចុប្បន្នពូនៅភូមិ ឃុំអីដែរ?

វ៉ៃ ៖ បច្ចុប្បន្ននៅភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ។

ប៊ុនថន ៖ បាទ!លោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

វ៉ៃ ៖ ខ្ញុំមានបងប្អូន៥នាក់ ។

ប៊ុនថន ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានលោកពូ?

វ៉ៃ ៖ ស្រី៣នាក់ ប្រុស២នាក់ ។

ប៊ុនថន ៖ លោកពូកូនទីប៉ុន្មាន?

វ៉ៃ ៖ ខ្ញុំកូនទី២ ។

ប៊ុនថន ៖ អញ្ជើញបងប្អូនពូនៅរស់ទេសព្វថ្ងៃ?

វ៉ៃ ៖ នៅរស់ទាំងអស់ ។

ប៊ុនថន ៖ នៅជុំគ្នាចុះឪពុកម្ដាយ?

វ៉ៃ : ម្ដាយនៅរស់ ឪពុកស្លាប់ ។

ប៊ុនថន : គាត់ស្លាប់យូរឬនៅលោកពូ?

វ៉ៃ : ស្លាប់តាំងពីជំនាន់៧២នោះយូរហើយ ។

ប៊ុនថន : ស្លាប់ដោយសារជំងឺឬក៏ដោយសារអី?

វ៉ៃ : គាត់ចាស់ជរា ។

ប៊ុនថន : ចុះម្ដាយនៅរស់សព្វថ្ងៃនៅបាត់ដំបង?

វ៉ៃ : នៅបាត់ដំបង គាត់ជរាហើយ គាត់៨០ជិត៩០ឆ្នាំហើយ ។

ប៊ុនថន : អ៊ូ!បានយូរណាស់ ចុះបងប្អូនអីគាត់នៅណា?

វ៉ៃ : បងប្អូននៅបាត់ដំបងខ្លះ នៅបន្ទាយមានជ័យខ្លះ ។

ប៊ុនថន : បាទ!ចុះលោកពូបានរៀនសូត្រអីដល់ណាខ្លះ កាលពីក្មេងៗ?

វ៉ៃ : ខ្ញុំពីជំនាន់នោះមិនបានរៀនសូត្រមិនបានជ្រៅជ្រះអីប៉ុន្មានទេ វានៅក្នុងសង្គ្រាមដូចរត់ទៅលិចរត់ទៅកើត ភៀសទៅលិចភៀសទៅកើតការៀនសូត្រអីបានតិច កាយលក៏បានតិច ។

ប៊ុនថន : បាទ!បានរៀននៅណាដែរពូសាលា?

វ៉ៃ : ខ្ញុំរៀននៅសាលាវត្តតាមឹមហ្នឹង ។

ប៊ុនថន : បាទ!រៀនបានប៉ុន្មានឆ្នាំលោកពូ?

វ៉ៃ : ខ្ញុំរៀនបាន២ឆ្នាំ រដ្ឋប្រហារទៅខ្ញុំទៅបួសៗនៅវត្តថ្វាក វត្តថ្វាកនៅបាត់ដំបង បួសបានមួយវស្សាក៏រដ្ឋប្រហារខ្ញុំក៏សឹកចូលព្រៃទៅ ចូលភ្នំវែចាបហ្នឹងទៅ រដ្ឋប្រហារលន់ណុលទម្លាក់សម្ដេចសីហនុហ្នឹង ដល់សឹកទៅចូលធ្វើខ្មែរអ៊ីសារ៉ាក់គេទៅ ។

ប៊ុនថន : កាលហ្នឹងចូលជាមួយពីណាលោកពូ?

វ៉ៃ : ចូលកាលហ្នឹងសម្ដេចអ្នកនាំចូល ។

ប៊ុនថន : សម្ដេចឪយើង?

វ៉ៃ : បាទ!សម្ដេចឪយើង ។

ប៊ុនថន : បាទ!ខាងហ្នឹងពួកណាអ្នកដឹកនាំព្រៃចាបហ្នឹង?

វ៉ៃ : ព្រៃចាបហ្នឹងតាអីទេ ចាស់ៗអស់ហើយភ្លេចអស់ហើយ នៅតំបន់ហ្នឹងតំបន់មួយហ្នឹងបើថាដឹកនាំសន្ដមពីសម័យនោះមាន ក្រុមភូមិដឹកនាំកាលហ្នឹងក្រោមការដឹកនាំរបស់

សម្តេចមានក្រុមភូមិដឹកនាំទៅ បង្កើតជាក្រុមតស៊ូប្រឆាំងជាមួយលន់ ណុល រហូតដល់សព្វថ្ងៃនេះទៅ ។

ប៊ុនថន : ប៉ុនចូលដំបូងខាងអ៊ីសារ៉ាក់ទេ?

វ៉ៃ : បាទ!ចូលមុនដំបូងសម្តេចបង្កើតខាងអ៊ីសារ៉ាក់ប្រឆាំង មានអីអ៊ីសារ៉ាក់មានតែចាស់ៗ កាន់តែកាំភ្លើងខ្វះអត់កាំភ្លើងផង កាំភ្លើងជំនាន់ហ្នឹងមានស្អីមានតែគ្រាប់១គ្រាប់ហ្នឹង មានអ្នកណាជួយកាលហ្នឹង ។

ប៊ុនថន : បាទ!គ្នាច្រើនទេកាលចូលដំបូង?

វ៉ៃ : ចូលដំបូងមាន៣ក្រុម មួយទៅកើត ក្នុងស្រុកក្នុងភូមិទៅ ចេះបំផុសគ្នាទៅនៅក្នុងព្រៃ ចេញចូលៗមិនទៅរកព្រៃអីសុទ្ធ កាលជំនាន់នោះព្រៃម្តុំចាប ម្តុំវង់អី ម្តុំជួរដងទឹកនោះសុទ្ធតែព្រៃ ។

ប៊ុនថន : បាទ!ចុះកាលហ្នឹងអត់មានខ្មែរក្រហមទេ?

វ៉ៃ : ខ្មែរក្រហមហ្នឹងកើតក្រោយអ៊ីសារ៉ាកទេ អ៊ីសារ៉ាក់ហើយបានកើតម៉ោខ្មែរក្រហម ខ្មែរក្រហមដឹកនាំមានខៀវ សំផន មានអីណាដឹកនាំជាមួយអាមេរិច ។

ប៊ុនថន : ពូនៅយូរទេ នៅភ្នំវាយចាបហ្នឹងរយៈពេលប៉ុន្មានពូ?

វ៉ៃ : ខ្ញុំនៅយូរ នៅខាងសំឡូតហ្នឹងយូរណាស់ ម៉ោដល់នេះជាមួយតាសូរតាអីហ្នឹង ។

ប៊ុនថន : និយាយពូរត់ចូលនេះកាលរដ្ឋប្រហារអីហ្នឹង លោកពូរត់ចូលភ្នំវ៉ៃចាបហ្នឹងរយៈពេលយូរទេ?

វ៉ៃ : នៅយូរនៅរហូតដល់ចប់៧៥បានចូលស្រុក ។

ប៊ុនថន : បាទ!នៅនោះគេបែងចែកម៉េចមិញពូពេលចូលទៅ?

វ៉ៃ : អត់មានបែងចែកម៉េចទេ ព្រោះខាងនយោបាយយើងថា កសិករក្រ មិត្តមានគេជិះជាន់អញ្ចឹងទៅ ប្រមូលបានតែកសិករក្រទេឲ្យចូលទៅ អ្នកមានគេមិនចូលទេ អញ្ចឹងកើតជារឿងថាបើមានការជិះជាន់អ្នកក្រអីអញ្ចឹង ។

ប៊ុនថន : ច្រើនគ្នាទេពូនៅភ្នំវាយចាបហ្នឹង?

វ៉ៃ : ពីដើមតែ៣ក្រុមទេ ហើយមួយឆ្នាំកើតបន្តិចៗ ដូចចេកអញ្ចឹងមុនដំបូងគេដាំតែមួយគុម្ពរួចម៉ោដុះកូន ដល់ដុះកូនយើងចេះតែដឹកកូនបំបែកដល់នេះវាចេះតែដុះទៀតទៅ ។

ប៊ុនថន : អញ្ចឹងបីក្រុមហ្នឹងមានមេដឹកនាំ៣នាក់?

វ៉ៃ : បាទ!មានមេក្រុម អនុក្រុម៣នាក់ ។

ប៊ុនថន ៖ ចុះពូនៅក្រុមពីណាវិញលោកពូ?

វ៉ៃ ៖ ខ្ញុំក្រុមជាមួយតាអីទេ ចាស់ហើយតាហ្នឹងកាលហ្នឹងគាត់នៅក្នុងស្រុកហ្នឹងដែរ គាត់ស្លាប់ហើយ ភ្លេចយូរហើយ ។

ប៊ុនថន ៖ មួយក្រុមប៉ុន្មាននាក់ដែរលោកពូ?

វ៉ៃ ៖ មួយក្រុមមាន១២នាក់ឡើង១៥នាក់ ។

ប៊ុនថន ៖ បាទ!ហើយមេដឹកនាំមួយក្រុមៗផ្សេងៗគ្នា?

វ៉ៃ ៖ បាទ!មួយក្រុមទៅយើងដឹកនាំបំបែកជាពួកទៅ មាន៣នាក់៤នាក់អញ្ចឹងទៅ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងមេអ៊ីសារ៉ាក់ដូចមាននៅខាងសៀមរាបឈ្មោះអីលោកពូ?

វ៉ៃ ៖ ភ្លេចអស់ហើយវាយូរទៅវាភ្លេច អត់មានក្រាំងមានបញ្ជីមានសៀវភៅអីមានឯកសារអីអត់មានរំសាយចោលតិចៗទៅ ។

ប៊ុនថន ៖ បាទ!ចុះពូនៅនោះដូចថាមានកាំភ្លើងមានអីរំពាក់ទេ កាលចូលទៅជាមួយអ៊ីសារ៉ាក់?

វ៉ៃ ៖ កាលចូលទៅពីដើមមានអាកាំភ្លើងយើងអាកាំភ្លើងកឹមគេ ប៉ិះស្តុងណា ៨ណាត់អីអស់ហើយអស់ស៊ុយ ប្រវត្តិហើយហ្នឹង សង្គ្រាមយើងទឹមកើតវាមិនសំបូរទេ ចាស់គេពីដើមគេច្នៃធ្វើអាកាំ ភ្លើងកឹបគេខ្វះទៅក្រតែដូងដាំងៗ ។

ប៊ុនថន ៖ ចុះកាលហឹងមានវៃជាមួយទាហាន លន់ ណុលអីទេលោកពូ?

វ៉ៃ ៖ វៃជាមួយទាហាន លន់ ណុល ។

ប៊ុនថន ៖ វៃនៅណាវិញលោកពូ?

វ៉ៃ ៖ ដូចថាទៅវៃអ៊ីសារ៉ាក់អញ្ចឹងទៅណា ទៅបាញ់ដូងដាំងៗទៅគេចដុតអស់ទៅ អត់មាននៅតតាំងអីយូរអី ដូចថាបាតដៃទទេអញ្ចឹង ភូដកៗក៏នាំគ្នាគេចអស់ទៅគេហៅការពារកម្លាំងអាវុធគ្រោះថ្នាក់ សង្គ្រាមយើងអត់មានអីធំដុំទេ គ្រាន់តែជានយោបាយ រួមផ្សំអាវុធតិចតួចទៅ ។

ប៊ុនថន ៖ បាទ!ដូចថាវៃឈ្លបអីអញ្ចឹង?

វ៉ៃ ៖ បាទ!វៃឈ្លបឆ្មក់អីអញ្ចឹងទៅ ។

ប៊ុនថន ៖ មានដែលវៃជាទ្រង់ទ្រាយធំទេ?

វ៉ៃ ៖ គ្មានទេ ក្រោយម៉ោរហូតដល់៧៥បានធំ ៧៤-៧៥ហ្នឹងលេងគ្នាហើយជួយគ្នាហើយមានចិនមានអីណាជួយលិចជួយកើត ជាមួយអាមេរិចហ្នឹងលេងគ្នាហើយដាច់ព្រាត់ហើយ ។

ប៊ុនថន : បាទ!អញ្ចឹងលោកពូនៅជាមួយអ៊ីសារ៉ាក់ហ្នឹង ក្រោយម៉េាជាមួយខ្មែរក្រហមយ៉ាងម៉េច ដែរលោកពូ?

វ៉ៃ : ក្រោយម៉េាវាចូលបន្តិចម្តងជាក្រុមមានដឹកនាំអីអញ្ចឹងដូចមាន ប៉ុល ពត មានខៀវ សំផន មានទួន ជាអីទៅ បង្កើតជាក្រុមធំទៅពង្រីកភូមិលិចកើងអញ្ចឹងទៅមានប្រជាជនអញ្ចឹងទៅវាកើតជាសង្រ្គាមធំឡើងច្រើន ។

ប៊ុនថន : បាទ!អញ្ចឹងចូលគ្នាហ្នឹងឆ្នាំប៉ុន្មានអីសារ៉ាក់?

វ៉ៃ : ដូចឆ្នាំ៦៩-៧០ហើយចូលធ្វើខ្មែរក្រហម ។

ប៊ុនថន : បាទ!៧០ហ្នឹងចូលម៉េា?

វ៉ៃ : បាទ!ចូលជាមួយខ្មែរក្រហម ៦៩អីហ្នឹងនៅជាមួយអ៊ីសារ៉ាក់ខ្ញុំមិនធំអីទេនៅជំទង់អីហ្នឹង បន្ទាប់ពីបួសទៅនេះ រត់តាមគេផ្ទាក់ៗទៅគេទៅកើតៗគេ គេទៅលិចៗគេទៅ ។

ប៊ុនថន : បាទ!៦៩ហ្នឹងចាប់ផ្តើមចូលជាមួយខ្មែរក្រហម?

វ៉ៃ : បាទ!ចូលគ្នាហើយ កាលហ្នឹងមានកម្លាំងច្រើនណាស់ អនុសេនាតូច វរៈសេនាធំ អនុសេនាធំអីអញ្ចឹងទៅ ទៅតាមតំបន់ដោយឡែកៗពីគ្នាវាកំពត តាកែវ បាត់ដំបង សៀមរាបអញ្ចឹងទៅ ។

ប៊ុនថន : បាទ!កាលហ្នឹងពូចូលកងពូហ្នឹងគេមានបែងចែកវរៈប៉ុន្មានៗទេពូ?

វ៉ៃ : កាលហ្នឹងដូចវរៈប៉ុន្មានទេ ដូច៣០២ឬក៏៥០២មិនដឹង ភ្លេចលេខហ្នឹងអស់ហើយយូរទៅវិលវល់ដូចថាវាសាបសូន្យវាភ្លេចអីអស់ទៅ ដូចថារស់ទៀត ។

ប៊ុនថន : បាទ!ចុះមានចាំកងពលអនុសេនាតូច អនុសេនាធំទេលោកពូ?

វ៉ៃ : ភ្លេចអស់ហើយ ។

ប៊ុនថន : គេរៀបចំប្តុនៅកាលពូចូលដំបូង?

វ៉ៃ : គេរៀប ប៉ុនភ្លេចអស់ហើយ ដូចវរៈសេនាតូចលេខ១៧ ។

ប៊ុនថន : ពូជាមួយពីណាពូកាលហ្នឹង?

វ៉ៃ : ខ្ញុំនៅជាមួយតា វ៉ន ខ្មោចតាវ៉ន ស្លាប់បាត់ហើយ តាវ៉ន តាហ៊ាបស្លាប់បាត់ហើយ នៅតំបន់៤ ។

ប៊ុនថន : បាទ!តំបន់៤ខាងភ្នំស្រុកខាងអីវិញពូ?

វ៉ៃ : ទេ!តំបន់៤ម៉ោយើងនេះម្តុំកាត់រទេះ ម្តុំយើងអូសទូកនេះ ហៅមាត់ទន្លេ ហៅតានាម និយាយរួមខាងនាមនោះ ខាងក្រោមថ្នល់នោះ គេចែកតំបន់នៅលើថ្នល់តំបន់១ ក្រោមថ្នល់តំបន់៤ ។

ប៊ុនថន : ចុះគាត់នៅរស់ទេលោកពូ តាវ៉ន?

វ៉ៃ : ស្លាប់អស់ហើយគាត់ចាស់ហើយ តាវ៉ន តាហ៊ាប តាម៉ុតអី ។

ប៊ុនថន : ចូលដំបូងមានហាត់ទេលោកពូ ដូចពូចូលទាហានអី?

វ៉ៃ : ហាត់ មើល៍ឆ្នាំ៧២នោះវាទៅយួននោះ ។

ប៊ុនថន : អ៊ូ!ពូបានទៅយួនដែរ?

វ៉ៃ : បាទ!ឆ្នាំ៧២ទៅលេងយួន ។

ប៊ុនថន : ទៅហាណូយក៏ទៅ?

វ៉ៃ : ទៅហាណូយហ្នឹងហើយ ទៅរៀនយួនបាន២ឆ្នាំបានឡប់ម៉ោវិញ ត្រឡប់ម៉ោវិញគេឲ្យយើងធ្វើប្រធានការណ៍ហាត់ហ៊ឹកហ៊ឺនកងទ័ពអញ្ចឹង រៀបតវិយាបថអីចេះចុះទៅសមរ ភូមិក្រាបលូនវាម៉េចអីម៉េចតាមបច្ចេកទេសសង្គ្រាមគេទៅ ។

ប៊ុនថន : បាទ!ទៅច្រើនគ្នាហាណូយ?

វ៉ៃ : កាលហ្នឹងម៉ាអន្តភាពទៅ៣នាក់ យកទៅរៀន ។

ប៊ុនថន : ពូហើយពីណាទៀតពូចាំឈ្មោះទេ?

វ៉ៃ : ស្លាប់អស់ហើយ តាំងពីម៉ោហ្នឹងធ្វើសង្គ្រាមស្លាប់អស់ហើយ នៅតែខ្ញុំមួយ ។

ប៊ុនថន : កាលហ្នឹងខ្ញុំទៅខាងថ្មពួកខ្ញុំពូពូម្នាក់ហ្នឹងគាត់ទៅវៀតណាម ទៅហាណូយដែរ កាលហ្នឹងថាតាញឹម អីទៅរៀនដែរពូ?

វ៉ៃ : តាញឹម?

ប៊ុនថន : បាទ!

វ៉ៃ : ទៅ តាញឹមគាត់ទៅ ។

ប៊ុនថន : តាញឹមគាត់ទៅមុនលោកពូ ឬទៅក្រោយលោកពូ?

វ៉ៃ : គាត់ទៅមុន ។

ប៊ុនថន : អញ្ចឹងគាត់ត្រឡប់មៅហើយបានពូទៅ?

វ៉ៃ ៖ បាទ!គេដឹកនាំទៅមុន គេទៅរៀននយោបាយស្អីៗគេទេ ខ្ញុំមិនដឹង រៀនសាលាតែមួយ គេទៅមុន យើងទៅក្រោយមិនដឹងគេរៀនអី អ្នករៀនមុនដឹងមុន អ្នករៀនក្រោយដឹងក្រោយ ។

ប៊ុនថន ៖ អញ្ចឹងទៅរៀននៅហ្នឹងរៀនយ៉ាងម៉េចបើពូអត់ចេះភាសាផង?

វ៉ៃ ៖ ទៅ មិនចេះក៏ត្រូវតែចេះ យើងរៀនហើយគេមានគេប្រែឲ្យយើងស្ដាប់ខ្មែរយើងទៅ យើងមានទៅថាយួននិយាយយួនខ្មែរអត់ចេះ យួនគេថាម៉េចខ្មែរគេថាម៉េចដល់អញ្ចឹង យើងដឹង ឲ្យខ្មែរបង្រៀនខ្មែរ ហើយយួនវាគ្រាន់តែឈរមើល ។

ប៊ុនថន ៖ បាទ!អ្ហូមានខ្មែរគេបង្រៀន?

វ៉ៃ ៖ បាទ!យួនវាឈរមើលហ្នឹងខុសគោះឯងផ្ទងអាហ្នឹងឆាប់ចេះណាស់ តែខុសវាអត់មានមាត់ទេវាគ្រាន់តែគោះ ។

ប៊ុនថន ៖ បាទ!ច្រើននាក់ទេលោកពូម៉ាក្រុមពូទៅរៀននៅនោះ?

វ៉ៃ ៖ មួយដងមានតែ៣០នាក់ ចប់ម៉ោវិញ ម៉ោវិញនាំអ្នកផ្សេងទៅទៀតមិនឲ្យទៅច្រើនទេ មិនឲ្យប៉ះពាល់ដល់កម្លាំង ហើយទៅតិចមៅវិញធ្វើការងារដឹកនាំអាច្រើនហ្នឹង បង្ហាត់អាច្រើនហ្នឹង គេមិនឲ្យទៅច្រើនមិនឲ្យទៅទាំងរយអត់ទេ ម៉ាក្រុមទៅតែ៣នាក់ហ្នឹងច្រើនពេកផង ដូចធៀបថាគ្រូបង្រៀនកូនសិស្សមួយថ្នាក់ប៉ុន្មាន ៥០នាក់ៗហ្នឹងមានគ្រូតែមួយទេ ហើយបង្រៀនកូនសិស្ស៥០នាក់ចេះ ។

ប៊ុនថន ៖ បាទ!ពូត្រឡប់ម៉ោវិញធ្វើអីដែរលោកពូ?

វ៉ៃ ៖ ធ្វើអនុសេនាធំ ។

ប៊ុនថន ៖ អនុសេនាធំ?

វ៉ៃ ៖ បាទ!កាលហ្នឹងមាន១០០នាក់ដាងដែរ ។

ប៊ុនថន ៖ កាលហឹងអនុសេនាធំលេខប៉ុន្មានលោកពូ?

វ៉ៃ ៖ ខ្ញុំអនុសេនាធមលេខ១២ វរៈសេនាតូចលេខ១៧ ។

ប៊ុនថន ៖ នៅខាងភូមិភាគពាយ័ព្យ?

វ៉ៃ ៖ បាទ!នៅខាងភូមិភាគពាយ័ព្យហ្នឹង នៅម៉ាជួរយើងដងស្ទឹងសង្កែ ម៉ោសំឡូតម៉ោអី នេះ ។

ប៊ុនថន ៖ បាទ!ពីណាដល់ណាលោកពូ កាលកន្លែងពូគ្រប់គ្រង?

វ៉ៃ ៖ តាមដងស្ទឹងម៉ោ ម៉ោតាមព្រៃម៉ាជួរយើងម៉ោដល់ព្រំដែនកាលហ្នឹង ម៉ោដល់ភ្នំយើងព្រំដែននេះនៅក្បែរៗភូមិហ្នឹង បើទៅឆ្ងាយពីភូមិវាអត់អីហូប ទៅដល់នោះយើងមានបាន

ធ្វើស្រែធ្វើចំការដូចឥឡូវនេះ  កាលនោះសម័យសង្គ្រាមកើតស្រែកើតចំការចិញ្ចឹងសេដ្ឋកិច្ចខ្លួនឯងខ្វះ  គេឲ្យខ្វះ  ហើយកាលហ្នឹងតែឆ្ងាយភូមិស្ងាប់ ។

ប៊ុនថន :  បាទ!កាលហ្នឹងកងពលលេខប៉ុន្មានពូ?

វ៉ៃ :  កាលហ្នឹងកងពលលេខប៉ុន្មាន  កាលហ្នឹងមិនទាន់កងពលអីធំដុំទេ  កាលហ្នឹងត្រឹមវរៈសេនាធំទេ ។

ប៊ុនថន :  ត្រឹមបង្កើតជាវរៈទេ?

វ៉ៃ :  បាទ!វរៈសេនាធំ  កងពលនៅដឹកនាំបណ្ដោយហ្នឹង  ឧទាហរណ៍មួយខែពីរខែគេដើរមកម្ដងអីនោះ  ហៅយើងប្រជុំអីចេះចុះទៅពីរឿងសង្គ្រាម  ថាឲ្យយើងចេះនៅក្នុងព្រៃ ។

ប៊ុនថន :  បាទ!

វ៉ៃ :  បើមិនអញ្ចឹងទេបោលចូលស្រុកអស់  បើអត់អីហូបផង ។

ប៊ុនថន :  បាទ!ពីណាលោកពូ  កាលហ្នឹងចុះទៅ?

វ៉ៃ :  កាលហ្នឹងមានតែតាៗៗឃើញគាត់ដើរ  មានតាម៉ុកអីហ្នឹង  ខស្សរាហ៍ដើរណាស់ ។

ប៊ុនថន :  គាត់ខស្សរាហ៍ទៅហ្នឹង?

វ៉ៃ :  បាទ!ខស្សរាហ៍មួយថ្មីកៗចេះតែដើរតាមហ្នឹង  មានអីជិនាន់ហ្នឹងមានតែដីរ  ជិះដីរ ។

ប៊ុនថន :  អ្ហូ!?

វ៉ៃ :  ដើរក្រឡឹងយប់ឡើងឆ្លងត្រង់ណា  ចន្លោះទាហានចន្លោះអីអញ្ចឹងទៅណា៎ ។

ប៊ុនថន :  អញ្ចឹង៧៣ហ្នឹងគាត់ទៅដល់នោះហើយតា១៥  តាម៉ុក?

វ៉ៃ :  អ្ហូ!គាត់ដើរតាំង៧២នោះ  គាត់ដើររហូតហ្នឹង ។

ប៊ុនថន :  គាត់ចុះទៅដល់ហ្នឹងដែរ?

វ៉ៃ :  បាទ!

ប៊ុនថន :  ចុះកាលពូម៉ោវរៈសេនាធំហ្នឹងតាញឹមគាត់នៅខាងហ្នឹងឬនៅពូ  រស់ញឹម?

វ៉ៃ :  រស់ញឹម  ទឹមរៀបចំយើង៧៥នេះទេ ។

ប៊ុនថន :  ទឹមរៀបចំក្រោយទេ?

វ៉ៃ :  បាទ!មោខាងភូមិភាគ៧៥នេះបាត់ដំបងនោះ ។

ប៊ុនថន :  បាទ!កាលជិនាន់ពូហ្នឹងអត់ទាន់មានអ្នកណាកាន់ច្បាស់ទេ៧៣?

វ៉ៃ :  នៅទេ!  នៅជាអគ្គភាពវរៈសេនាតូច  វរៈសេនាធំ  វាច្បាស់លាស់ហើយ  ប៉ុនអ្នកធំៗច្បាស់លាស់ហ្នឹងគេមិនដែលម៉ោញឹកញយទេ  ម៉ោ១ឆ្នាំអីម៉ោ១ម្ដងគេហៅទៅមើលមេ

ធំៗ គេប្រជុំអញ្ជើងទៅណា ឲ្យទៅរៀនសូត្រអីអញ្ជើងទៅ ហើយអ្នកណាតូចតាចនៅយាមព្រៃទៅ ។

ប៊ុនថន : បាទ!

វ៉ៃ : បាទ!អញ្ជើងអាហ្នឹងពីជំនាន់ហ្នឹង ។

ប៊ុនថន : ហើយតាម៉ុក កាលហ្នឹងមានតួនាទីអីដែរពូកាល៧៣ទៅហ្នឹង?

វ៉ៃ : គាត់ខាងយោធា តាម៉ុកខាងយោធា ។

ប៊ុនថន : ចុះផ្សេងពីគាត់មានទៅទេពូ?

វ៉ៃ : ទៅមានអ្នកណាមានតែនួន ជា ។

ប៊ុនថន : នួន ជាគាត់ទៅដែរ?

វ៉ៃ : បាទ!នួន ជាពីដើមនៅបាត់ដំបងហ្នឹងចិនកាប់ជ្រូកបាត់ដំបង ។

ប៊ុនថន : គាត់នៅតាមផ្ទះគាត់នៅស្ទឹងសង្កែហ្នឹង?

វ៉ៃ : បាទៗ !នៅវត្តគរ ។

ប៊ុនថន : បាទៗ !តាមមាត់ស្ទឹងហ្នឹងខ្ញុំទៅឃើញ?

វ៉ៃ : ពីដើមគាត់ចិនកាប់ជ្រូក ។

ប៊ុនថន : អ្ហូ!ពូស្គាល់គាត់ច្បាស់ទេពូ?

វ៉ៃ : ហ៊ឺ!នៅព្រៃទឹមបែកគ្នារៀនចប់ទៅណាទៅណីអស់ទៅ ។

ប៊ុនថន : បាទ!?

វ៉ៃ : ពីដើមយើងនៅតែជិតគ្នាហ្នឹង ។

ប៊ុនថន : តើគាត់មានបងប្អូនប៉ុន្មាននាក់ពូ នួន ជា?

វ៉ៃ : ទេអត់ដឹងទេរឿងបងប្អូនមិនសូវដឹងដែរ គាត់មនុស្សស្លូតដែរហ្នឹង នួន ជា ប៉ុនគាត់ម៉ឺងម៉ាត់បន្តិចគាត់និយាយម៉ាត់ណាម៉ាត់ហ្នឹង បើថាយើងអត់ចេះអក្សរអត់ចេះអីហ្នឹងគាត់រកប្រជុំយើងឲ្យ៣ខែឲ្យជួបគ្នាមួយដងចេះបានប៉ុន្មាន អីអញ្ជើងទៅក៏ខំរៀន ៣ខែចេះមិនម៉ក់៣ខែទៀតប៉ុនចេះមើល ។

ប៊ុនថន : អ្ហូ!គាត់ដាក់កាលវិភាគឲ្យមើលហ្នង?

វ៉ៃ : ដាក់យើងខំហ្នឹង ៣ខែម៉ោទៀតគាត់ថាអាហ្នឹងគ្រាន់ខំទៀត ។

ប៊ុនថន : ប៉ុនមានដឹងប្រវត្តិគ្រួសារគាត់ឪពុកម្តាយគាត់អីទេ?

វ៉ៃ : ហ៊ឺ!អត់ដឹងទេ ដឹងតែគាត់ហ្នឹង ហើយគ្រួសារគាត់យាយ សេមហ្នឹងប៉ុនមិនដឹងគាត់ស្លាប់ឬនៅបែកយូរហើយ ។

ប៊ុនថន : ឈ្មោះអីពូ?

វ៉ៃ : យាយ សេម ។

ប៊ុនថន : សេម?

វ៉ៃ : បាទ!

ប៊ុនថន : ស្អី សេមពូ?

វ៉ៃ : ស្អីសេម ទេគេហៅតែគាន្ធន យាយសេមៗ ប្រពន្ធគាត់សស្តើងទេ កូនរបស់គាធឿន កូនស្រីរបស់គាធឿន ។

ប៊ុនថន : ប៉ុន្មានកូនពូ?

វ៉ៃ : កូនដូច២នាក់កូនចិញ្ចឹម ប៉ុន្មាននាក់ទេកូនតិចដែរហ្នឹង បើពូធឿននោះបងគេបន្ទាប់មៅបានពូសាយ ទៅណាទៅណីអស់ហើយបែក ឃើញក៏ជួបក៏មិនស្គាល់ដែរឥឡូវនេះ ។

ប៊ុនថន : បាទ!ហើយគាត់បានទៅរៀននៅថៃនៅអីពូ?

វ៉ៃ : ខ្ញុំហ្នឹង?

ប៊ុនថន : អត់ទេពូន្ធន ជា?

វ៉ៃ : ទេ!ពីដើមគាត់នៅព្រំប្រទល់ដីថៃ កាលយើងសង្គ្រាមគាត់ធ្វើផ្ទះធ្វើអីនៅដីថៃនោះ ។

ប៊ុនថន : បាទ! គាត់ថាបានទៅរៀនចប់នៅសាលានៅថៃលោកពូ?

វ៉ៃ : បាទ!អត់សូវដឹងទេ ។

ប៊ុនថន : បាទ!អញ្ចឹងលោកពូនៅហ្នឹងមានដែលដឹកនាំវ៉ៃប៉ះជាមួយទាហានលន់ ណុលអីទេ ហើយនៅខាងណាៗខ្លះទេពូ?

វ៉ៃ : អ៊ើ!ពីជំនាន់មុននោះវាផុតាហើយ ។

ប៊ុនថន : មុន៧៥ពូ កាលពូនៅវរៈសេនាធំ អាហ្នឹងលន់ ណុលវ៉ៃខ្លាំងមានតែកោះក្រឡអីហ្នឹងស្គាល់កោះក្រឡហ្នឹងក៏ដាក់គ្នាខ្លាំងដែរហ្នឹង ដាក់ឡើងរលាយព្រះវិហាររលាយអីអស់ ។

វ៉ៃ : លាយគ្នានៅហ្នឹងលោកពូ?

ប៊ុនថន : បាទ! ទាហានវានៅក្នុងវត្តហើយដាក់គ្នាហ្នឹង ដឹកដល់វ៉ៃគ្នាមែនទែនទៅដឹកយកផ្លូវដើរដងទឹកដឹក ឡើងលើមិនកើតខ្លាចគេឃើញ ហើយចេះតែដឹកទៅ ដល់លិចក្បាលយើងដើរយកទឹកយកអីដឹកទៅ ពិបាកដែលហ្នឹងវាសង្គ្រាមវាមិនស្រួកទេឈ្មោះថាសង្គ្រាម មួយ

អញ្ចឹងបានថាដល់ចប់ប៉ុនវាស្រួល បើស្រួលហើយមិនធ្វើមិនរកទៀតវាពិបាកទៀតពិបាលលើសអាសន្រ្គាមទៀត អាមិនធ្វើហើយសង្រ្គាមដូចតែគ្នា តែមិនធ្វើអត់អត់ពិបាក អាសង្រ្គាមបើយើងមិនច្បាំងមិនធ្វើអត់អីស៊ីដែរ តែចាញ់គេរត់ហត់ផាប់ៗ អាហ្នឹងម្តងម្នាក់ទេអារឿងចាញ់ឈ្នះមើលមិនឃើញ ឈ្នះទៅគ្រាន់បើចាញ់រត់ហាមាត់ដូចតែគ្នាហ្នឹង ។

វ៉ៃ : វ៉ៃបែកទេលោកពូនៅកោះក្រឡ?

ប៊ុនថន : បែក ។

វ៉ៃ : បែកខាងលន់ ណុល?

ប៊ុនថន : បាទ! ពុវ៉ៃតែមុខព្រួញកោះក្រឡ មានទៅខាងណាផ្សេងទៀតទេលោកពូ?

វ៉ៃ : វ៉ៃវាគ្រប់តែនេះហ្នឹងប៉ុនវារបេសរបោះៗ គ្មានអីទេ ទល់៧៥ហើយបានយើងវ៉ៃបោសតាមផ្លូវជាលេខចូលបាត់ដំបង ពួកវាម៉ោចាំ ។

ប៊ុនថន : វ៉ៃបែកហ្មង?

វ៉ៃ : បាទ! ៧៥ បែក ។

ប៊ុនថន : បែកភ្លាមហ្នឹងមានដូចថាមានប្រជុំមានអីទេលោកពូ?

វ៉ៃ : ហ៊ឺ!បែកភ្លាមហ្នឹងគ្មានអ្នកណាបានប្រជុំបានអីទេ វាដោយសារថាជ័យជំនះ អ្នកខ្លះទាញម៉ូតូបើកឡានក្រឡាប់បុកគ្នាផាប់ ដូចថាវាភ្លើតភ្លើនយើងនៅក្នុងព្រៃ ចូលក្រុងម្តងៗញ៉េញ៉ាវឡានបុកតែគ្នាឯងហ្នឹង អាខ្លះជិះម៉ូតូរកកន្លែងឈប់មិនឃើញធ្លាក់ទឹកដូង ។

ប៊ុនថន : អ៊ូ!មានអញ្ចឹងដែរ?

វ៉ៃ : ចុះធម្មតាមនុស្សវាអត់ចេះបើក ។

ប៊ុនថន : អត់ចេះបើក?

វ៉ៃ : អត់ចេះបើកចេះតែពួយទៅដល់កន្លែងឈប់ទេដល់អស់សាំងរលត់ហ្មង មិនដូចក្មេង ឥឡូវមិនចេះមើលកង់ទ័រ ប្រេងជិតអស់មិនអស់អីទេ ចេះតែពួយទៅ ខ្លះក៏ចាប់អាប្រាំងមុខដួលបាក់កផាប់ក៏មាន ខ្លះវិញបុកគ្នាទៅ ជំនាន់ហ្នឹងផាប់មានតិចទេ អាច្បាំងផាប់មួយសារ អាបុកគ្នានេះផាប់មួយសារទៀតទៅ ។

ប៊ុនថន : បាទ!ដល់ពេលអញ្ចឹងមានដូចថាមានអ្នកណែនាំអីទេពូ?

វ៉ៃ : ដល់ហើយបានណែនាំ មានច្បាប់មានអីចរាចរណ៍រៀនសូត្រ មានអ្នកចេះតិចទៅមានអ្នកអត់ចេះច្រើនទៅណា៎ ចេះតែបង្រៀនបន្តគ្នាទៅ ការរៀនសូត្រពីដើមល្ងង់ខ្លៅ

ណាស់ចាស់ៗពីដើម ឲ្យទៅរៀនទៅសូត្រទៅបានចេះដឹងតិចៗទៅ ខ្ញុំជិនាន់ហ្នឹង៧៥ ហ្នឹងជាប់គុកដែរហ្នឹង គេចោទពួកពាយ័ព្យចេះចុះជាប់គុកព្រៃសរបាន១ឆ្នាំគេទៅ ហើយនេះគេឲ្យចេញម៉ោវិញម៉ោវាអត់មានកំហុសអី ។

ប៊ុនថន : បាទ!ជាប់គុកនៅណាវិញលោកពូ?

វ៉ៃ : នៅព្រៃសរនៅភ្នំពេញ ។

ប៊ុនថន : គុកព្រៃសរដែលគេហៅមន្ទីរសរ២៨ហ្នឹងពូ?

វ៉ៃ : ឌុច ហៅអាវហ្នឹង ។

ប៊ុនថន : បាទៗ! ព្រៃសរហ្នឹងហៅមន្ទីរសរ២៨ ហើយទួលស្លែងហ្នឹង ស២១ពូ?

វ៉ៃ : បាទ!ហ្នឹងហើយ បានតាឌុចហ្នឹងទេស្គាល់គេធ្វើប្រធានគាត់ថា ហ៊ី!ចុះវ៉ៃឯងម៉ោធ្វើអី ខ្ញុំថាហ៊ី!ម៉ោធ្វើអីម៉េចចាប់ខ្ញុំដាក់លើឡានហើយមកសួរម៉ោអញ្ចឹង ។

ប៊ុនថន : អ្ហូ!ប៊ុនម៉ោចូលដំបូងហ្នឹង ម៉ោព្រៃសរហ្នុងឬទៅទួលស្លែងពូ?

វ៉ៃ : មុនដំបូងទៅទួលស្លែងសិន ចេញពីទួលស្លែងបានទៅព្រៃសរ មិនថាអីទេខ្ញុំមិនថាតាឌុច ហ្នឹងយោរយៅគេសម្លាប់ចោលបាត់ហើយ គេយល់ទៅរកនេះទៅរកនោះ ។

ប៊ុនថន : ប៊ុនលោកពូស្គាល់ឌុចនេះស្គាល់តាំងពីអង្កាល់ពូ?

វ៉ៃ : ស្គាល់យូរហើយឌុចហ្នឹង គាត់របួសដៃនេះមើលដៃគាត់ ខ្ញុំឲ្យកាំភ្លើងមួយដើមទៅជូន កាលប្រពន្ធកាច់កែទៅដូងងាប់អស់ ។

ប៊ុនថន : ប្រពន្ធកាច់កែ?

វ៉ៃ : ប្រពន្ធប្ដីលាង ប្រពន្ធទៅដល់អត់មានសួរគាត់ទៅដល់ប្រពន្ធកាច់ដូង ។

ប៊ុនថន : បាទ!ប្រពន្ធគាត់ឈ្មោះយាយ រុំហ្នឹង?

វ៉ៃ : បាទ!ខ្មៅព្រីក ។

ប៊ុនថន : បាទ!តាំងពីឆ្នាំប៉ុន្មានពូស្គាល់ឌុចហ្នឹង?

វ៉ៃ : រាប់ឆ្នាំយូរដែលហើយ កូនគាត់តែ៣នាក់ទេ ស្រី១ប្រុស២ ក្រោយទៀតមិនដឹងម៉េច ទេមិនដឹងកើតប៉ុន្មាន ។

ប៊ុនថន : ស្គាល់នៅណាវិញពូ កាលស្គាល់គាត់ដំបូង?

វ៉ៃ : គាត់ម៉ោនៅសំឡូត ។

ប៊ុនថន : គាត់ម៉ោនៅសំឡូតដែរ?

វ៉ៃ : បាទ!តិចគាត់កូនតាឌុចទៅ?

ប៊ុនថន ៖ បាទ!ខ្ញុំនេះ?

វ៉ៃ ៖ បាទ!

ប៊ុនថន ៖ អ៊ូ!អត់ទេ ខ្ញុំម៉ោធ្វើការនេះផ្សេងហ្នឹង អ៊ូ!គាត់របួសដៃហ្នឹងក្រោយម៉ោហើយ?

វ៉ៃ ៖ ក្រោយទេម៉ោចប់៧៥ហើយ ព្រួសូរចូល៧៩ហើយបានត្រូវដៃ ។

ប៊ុនថន ៖ ប៉ុនលោកពូស្គាល់គាត់ហ្នឹងតាំងពីមុនរំដោះភ្នំពេញឆ្នាំ៧៥ លោកពូ?

វ៉ៃ ៖ បាទ!

ប៊ុនថន ៖ ស្គាល់នៅណាវិញលោកពូ កាលស្គាល់គាត់ដំបូង?

វ៉ៃ ៖ កាលហ្នឹងគាត់នៅណាទេ ស្រុកណាយូរហើយចង់ភ្លេច?

ប៊ុនថន ៖ កាលគាត់ឈប់រៀនហើយ គាត់ទៅខាងកំពង់ចាមពូ?

វ៉ៃ ៖ បែបហ្នឹងមិនដឹង ។

ប៊ុនថន ៖ បាទ!ហើយម៉េចបានស្គាល់ពូកាលហ្នឹង?

វ៉ៃ ៖ ស្គាល់តាមខ្សែរយៈដូចថា ម៉ោភូមិនេះមានឈ្មោះនេះឈ្មោះនោះអញ្ចឹងទៅណាស់ ដូចតែអាប៉ោងអញ្ចឹងវិលចុះវិលឡើងវាស្គាល់គ្នា យើងនេះនោះៗទៅស្គាល់គ្នា ។

ប៊ុនថន ៖ ពូជិតស្និតជាមួយគាត់ទេពូ ដូចថារាប់អាន?

វ៉ៃ ៖ ជិតស្និត សួរទៅ ប្រាប់តែឈ្មោះខ្ញុំគាត់ស្គាល់ ឈ្មោះ វ៉ៃនៅសំឡូតៗ ។

ប៊ុនថន ៖ បាទ!ហើយចង់សួរពូថាពេលគេចាប់ទៅហ្នឹង មូលហេតុអីបានគេចាប់យកទៅ?

វ៉ៃ ៖ កាលហ្នឹងគេថាភូមិភាគនេះក្បត់ ភូមិភាគហ្នឹងក្បត់អញ្ចឹងទៅ ដូចថាតាញឹម ក្បត់អញ្ចឹងទៅគេចាប់តាញឹមទៅម៉ោលេងទាហានមេក្រុម គេចាប់វរៈសេនាអីអញ្ចឹងគេចាប់បន្តគ្នាអញ្ចឹង ហើយមិនដឹងអ្នកណាក្បត់អ្នកណាមនក្បត់យើងម៉េចដឹង ។

ប៊ុនថន ៖ កាលហ្នឹងចាប់តាញឹមរួចឬនៅពូ?

វ៉ៃ ៖ រួចហើយ ។

ប៊ុនថន ៖ បាទ!ចាប់បានរយៈពេលប៉ុន្មានបានម៉ោចាប់ពូទៀត?

វ៉ៃ ៖ ចាប់បានរយៈពេលជិតមួយឆ្នាំ ចាប់យកពីប៉ៃលិនទៅ កាលហ្នឹងខ្ញុំនៅប៉ៃលិននៅព្រំ ដែនចាប់ទៅដេកបាត់ដំបងមួយយប់បានហួសទៅភ្នំពេញ ។

ប៊ុនថន ៖ ចាប់ហ្នឹងខាងណាម៉ោចាប់ពូ?

វ៉ៃ ៖ ខាងណាទេ ខាងតាកែវ កំពតណាទេ ខាងនិរតីគេម៉ោចោទថាពាយ័ព្យក្បត់គេចាប់ ចាប់ពេញតែស្រែពេញស្រូវ កាលហ្នឹងរៀននយោបាយស្អីទេមិនសូវដឹងដែរចប់ទៅ ហើយកម្ពុជាកម្មការមិនចេះអស់មិនចេះហើយ ។

ប៊ុនថន ៖ បាទ!ចាប់ពូទៅពីប៉ៃលិនហ្នឹងទៅប៉ុន្មាននាក់ពូ ចាប់តែម្នាក់ឯងទេឬមានគេទៅជាមួយទៀត?

វ៉ៃ ៖ អេ៎!មានម្នាក់ទេ ចាប់បោះលើឡានហ្មង របៀបអាឡានចិននេះ ដៃចងជាប់ចេះលើកបោះៗអាឡានចិន ។

ប៊ុនថន ៖ គេម៉ោចាប់ហ្នឹងពូមានដឹងខ្លួនទេម៉ោចាប់?

វ៉ៃ ៖ គេហៅម៉ោរៀនសូត្រជុំគ្នាគេចាប់តែម្ដង មានម៉ោដល់ចាប់លោកឯងអត់ទេ ហៅម៉ោព្រឹបៗហើយ ។

ប៊ុនថន ៖ មានដូចថាមានគេសួរថាពូមានកំហុសអីអត់ទេ?

វ៉ៃ ៖ អ្ហូ!គេអត់មានសួរទេ អត់មានសួរគេថាយើងមានកំហុសអីទេ គេថាទៅរៀនទៅបាត់រហូត ។

ប៊ុនថន ៖ បាទ!ពេលចាប់ពូហើយហ្នឹងពូដឹងខ្លួនថាខុសអីទេពូ?

វ៉ៃ ៖ ទេអត់មានដឹងខ្លួនថាខុសអីទេ ឃើញថាគេចោទថាពួកពាយ័ព្យក្បត់អញ្ចឹងទៅ ហើយយើងថាក្បត់យ៉ាងម៉េចបើខំតស៊ូខំប្រឹងប្រែងហើយបើថាក្បត់ ក្បត់ម៉េច អានេះយើងថាចាត់ខ្លួនយើងថាអញ្ចឹងណាស់ ។

ប៊ុនថន ៖ បាទ!

វ៉ៃ ៖ បាទ!បើយើងទោសម្លាប់គេ ទៅប្លន់គេអីទៅអាហ្នឹងបានវាថាខុស អានេះយើងទៅការពារនៅព្រំដែនដូចនៅប៉ៃលិនណោអីទៅខុសអី យើងពិចារណាថាខុសអី ដូចថាយើងទៅធ្វើរបងបង្គោលប្រាក់អញ្ចឹង ទៅដល់គេដកបង្គោលប្រាក់បោះលើឡាននេះមិនប្រហែងចន្លោះហ្នឹងមិនអញ្ចឹង?

ប៊ុនថន ៖ បាទ!ហើយកាត់ម៉ោពីប៉ៃលិនម៉ោបាត់ដំបង?

វ៉ៃ ៖ បាទ! ដេកបាត់ដំបងមួយយប់ ហើយជិតភ្លឺហ្នឹងទៅទៀត អត់មានចាំភ្លឺទាន់ទេ ។

ប៊ុនថន ៖ បាទ!ឡើងម៉ោដល់ភ្នំពេញ?

វ៉ៃ ៖ ឡើងម៉ោដល់ភ្នំពេញចាំតប់បានគេចូល អត់ចូលថ្ងៃទេ ។

ប៊ុនថន ៖ អ្នកដែលម៉ោចាប់ពូហ្នឹងប៉ុន្មាននាក់ពូ?

វ៉ៃ : ទេ!ដូចអត់មានច្រើនទេ វិធីគេចាប់ហ្នឹងដូចថាគេហៅទៅ ចុចឈ្មោះហៅទៅរៀន នៅ ណា ទៅបាត់ដំបងឬក៏ទៅរៀនភ្នំពេញអញ្ចឹង អាហ្នឹងវិធីគេចាប់ហ្នឹងអត់មានអីនេះទេ ពូស្រែកញ៉ៅវិញ៉ៅវទេ គេធ្វើវិធីគេស្អាតណាស់ វាថាយើងទុកចិត្ត ប៉ុនបើដឹងថាគេចាប់ ហ្នឹងយើងម៉ោព្រាតពេញព្រៃអស់ឥឡូវហ្នឹង គ្មានអ្នកណាឲ្យចាប់ទេ ព្រោះការលំបាក ម៉ោយូរឆ្នាំហើយ យើងរស់ឲ្យគេចាប់យកទៅសម្លាប់ចោលអ្នកណាគេព្រមទាំងយើង ទាំងគេមិនអញ្ចឹង ។

ប៉ុនថន : បាទ!

វ៉ៃ : រត់បែកធ្វើម៉េចឲ្យតែរស់ រឿងស្លាប់គ្មានអ្នកណាចង់ស្លាប់ទេ ខំពីតូចម៉ែឪខំចិញ្ចឹមរហូត ដល់ប៉ុនៗនេះហើយ ដូចរាល់ថ្ងៃអញ្ចឹងចង់តែរស់ទេគ្មានអ្នកណាចង់ស្លាប់ទេ ។

ប៉ុនថន : បាទ!ចុះពូចូលដំបូងហ្នឹងទៅដល់ភ្នំពេញហ្នឹងយប់ដែរ កាលពូទៅ?

វ៉ៃ : បាទ!ចូលយប់ ស្ទើលហ្នឹងអីដល់គេអត់ចូលថ្ងៃ ។

ប៉ុនថន : ហើយចុះដំបូងហ្នឹងពូចូលទៅដល់ណាវិញពូ?

វ៉ៃ : ចូលទៅហ្នឹងមានដូចថាប្រធានគេនោះមួយអញ្ចឹង ហើយគេកត់ឈ្មោះកត់អីហើយគេ បញ្ចូលក្នុងគុកស្រេច អាចម៍ដាក់បាតអញ្ចឹងទៅ បាតដូចបាតលោកអញ្ចឹង ម្នាក់ឲ្យកាន់ បាតមួយ ។

ប៉ុនថន : ចូលទៅគេកត់ឈ្មោះពូ?

វ៉ៃ : បាទ!

ប៉ុនថន : ចុះពូមានចាំនៅម្តុំណាទេពូទៅដំបូង ចូលម្តុំណា?

វ៉ៃ : ចាំម្តុំណាម៉េច?

ប៉ុនថន : កាលពូចូលទៅដំបូង ពូទៅដល់គេកត់ឈ្មោះហ្នឹងនៅភ្នំពេញឬនៅក្រៅភ្នំពេញ?

វ៉ៃ : មិននៅភ្នំពេញទេ នៅហួសភ្នំពេញ និយាយរួមទៅដូចគេចងមុខឡានមិនឲ្យយើងឃើញ ខាងណាខ្ទបជិតមើលស្អីមើលតែដំបូលឡាន បិទដញ្ចាំងឡានសងខាងមិនដឹងដល់ណា ។

ប៉ុនថន : បាទ!អញ្ចឹងចងមុខពូតាំងពីនេះទៅ?

វ៉ៃ : មិនចងចទេ គេដាក់ក្នុងឡានទៅហើយវាជិត យើងមើលមានឃើញស្អី ឧទាហរណ៍ថា ដល់កំពង់ឆ្នាំង ដល់ពោធិ៍សាត់អីមានដឹងដល់ណាបើងងឹតឈឹងហ្នឹង ខ្ទបអត់មាន ប្រហោងឃើញបើតង់ហ្នឹងមានប្រហោងអីឃើញ ។

ប៉ុនថន : ចុះទៅដល់ភ្នំពេញហ្នឹងទៅដល់កន្លែងកត់ឈ្មោះហ្នឹងមានឃើញចងមុខអីទេពូ?

វ៉ៃ ៖ អត់ចង់ទេ ។

ប៊ុនថន ៖ អត់ចង់ទេបណ្តើរពូចូល?

វ៉ៃ ៖ បាទ!

ប៊ុនថន ៖ ចុះទៅដល់ភូមហ្នឹងពូអត់ទាន់បានជួបគាឌុចភ្លាមទេពូ?

វ៉ៃ ៖ នៅមិនទាន់ជួបទេ ទោបានប្រហែលជាកន្លះឆ្នាំបានជួប ដល់ជួបអស់សាច់បាត់ហើយ ស្គមស្រាប់ផង ដល់ជួបគាឌុចៗថាអេ៎! ខ្ញុំថាអេ៎!ម៉េចយូរណាស់ហើយក៏មិនម៉ោដល់ជិតផាប់ហើយបានម៉ោ ។

ប៊ុនថន ៖ ពូនិយាយអញ្ចឹងហ្នងប្តូក៏?

វ៉ៃ ៖ បាទ! ខ្ញុំនិយាយអញ្ចឹង ខ្ញុំថាយូរណាស់មិនម៉ោជិតផាប់ហើយបានម៉ោ ។

ប៊ុនថន ៖ ហើយគាត់ឆ្លើយថាម៉េចទៅ?

វ៉ៃ ៖ ឆ្លើយថាអញអត់ដឹងទេអាមិត្តឯងម៉ោ ឆ្លើយតែប៉ុន្នឹង ដល់ហើយដូចគេខ្សែបខ្សឹបគ្នាម៉េចទៅគេឲ្យចេញម៉ោស្រុកម៉ោភូមិវិញ ចេះរួចមាំគ្រាហ្នឹងចេះរស់ដល់សព្វថ្ងៃហ្នឹងដូចថាបុណ្យពីជាតិមុនម៉ោ ថាកម្ររួចណាស់កម្របានរស់ណាស់បើទៅដល់នោះហើយ ។

ប៊ុនថន ៖ បាទ!ចុះនៅនោះមានធ្វើទារុណកម្មអីទេនៅស២៤នោះពូ ព្រៃសរនោះ?

វ៉ៃ ៖ អត់ទេ! ទៅអត់ទាន់មានធ្វើអី ធ្វើទារុណកម្មតែប៉អីអត់ទាន់មានទេ បើថាដល់ពេលគេដើររាប់ទៀតគេដាក់អស់សាច់យូរៗទៅមិនផាប់ ។

ប៊ុនថន ៖ បាទ!មានឲ្យពូចេញធ្វើស្រែធ្វើអីទេពូ?

វ៉ៃ ៖ បើធ្វើស្រែធ្វើនឹងចបអាហ្នឹងមាំគន្ទាក់ អាហ្នឹងខាងយោធាហ្នឹង ធ្វើស្រែធ្វើអីហ្នឹងម៉ោងពាជិតភ្លឺនោះបាននៅអង្គុយសង្កុកនៅភ្លឺស្រែហ្នឹងងឹតឈឹង ដល់ភ្លឺបានឲ្យធ្វើ ហើយម្នាក់ៗអត់មានសាច់ទេ ក្បាលជន្លង់ធំជាងភ្លៅទៀតជំនាន់នោះវា អ៊ើ! គេថាទារុណកម្មហ្នឹង យើងខុសស្អីពីជាតិណាម៉ោបើយើងធ្វើសង្គ្រាមពីជាតិណាម៉ោ ដល់ចប់ទៅទៅធ្វើអញ្ចឹងនយោបាយអីដឹងដឹកនាំអី ដល់រកោយនេះចូលព្រៃទៀតហើយ ដោយសារឃ្លួនទេៗវាពូជសាសន៍ខុសគ្នា ។

ប៊ុនថន ៖ បាទ!

វ៉ៃ ៖ បើថាខ្មែរដូចមុនអត់មានធ្វើអីទៀតទេ តែឃ្លួនទេអ្ហ៎!ថាឃ្លួនឈ្លានពាន ។

ប៊ុនថន ៖ អញ្ចឹងពូទៅព្រៃសរហ្នឹងពូនៅជាប់ឃុំរហូតប្តូក៏គេឲ្យដើរ?

វ៉ៃ ៖ គេឲ្យចេញដើរ ។

ប៊ុនថន : ចេញដើរហើយធ្វើអីខ្លះពូនៅហ្នឹង?

វ៉ៃ : ចេញដើរទៅសំអាតនេះនៅជុំវិញអញ្ចឹងទៅ ។

ប៊ុនថន : បាទ!ក្រៅពីពូ ពូមានស្គាល់អ្នកផ្សេងដែលធ្លាប់ធ្វើការនៅហ្នឹងដែលទេ?

វ៉ៃ : ស្គាល់ប៉ុនដូចភ្លេចបាត់អស់ហើយ ដូចថា១០០លួចចេញតែខ្ញុំ១ហ្នឹង ហើយក្រៅពីហ្នឹងគេម៉ោផុតហើយមិនដឹងទៅណាមិនដឹងស្លាប់មិនដឹងរស់ ។

ប៊ុនថន : ប៉ុនអ្នកហ្នឹងខាងទាហានទាំងអស់ដែលពូ?

វ៉ៃ : ទាហានខ្មែរក្រហមយើងហ្នឹង ។

ប៊ុនថន : ប៉ុនអ្នកជាប់នៅនោះភាគច្រើនឋានៈជាអីវិញជាប្រធានៗ?

វ៉ៃ : ដូចថាប្រធាន"គ"អញ្ចឹងឥឡូវវរៈសេនាតូច វរៈសេនាធំទៅដាច់មួយខ្សែកៗគ្នាទៅអាណាធំក៏ធ្ងន់ទៅ អាណាតូចរាងស្រាលបន្តិចទៅ ។

ប៊ុនថន : បាទ!ចុះមានធំជាងពូទៀតទេ?

វ៉ៃ : ធំមានវរៈសេនាធំមាន អាហ្នឹងគេដាក់មួយខ្សែក ។

ប៊ុនថន : មាននៅចាំឈ្មោះខ្លះទេពូ?

វ៉ៃ : អ្ហូ!ភ្លេចអស់ហើយ វាគ្មានចិត្តអីដូចថាខួរក្បាលចាំរឿងអញ្ចឹងៗ វាពន្ធត់ខួរក្បាលកុំឲ្យនឹកឃើញ ។

ប៊ុនថន : បាទ!ចុះអ្នកនៅហ្នឹងពូមានស្គាល់ទេនៅព្រៃសហ្នឹង?

វ៉ៃ : ស្គាល់តែតាឌុចមួយហ្នឹង ។

ប៊ុនថន : មានស្គាល់ នន់ ហ៊ុយអីទេពូ?

វ៉ៃ : អ៎!ខ្ញុំមិនបានស្គាល់ទេ ស្គាល់តែតាឌុចស្គាល់ដោយសារនិយាយលេងច្រើន ខស្សាហ៍និយាយលេងច្រើនណាស់តាហ្នឹង ។

ប៊ុនថន : បាទ!គាត់និយាយលេងពីអីខ្លះពូ?

វ៉ៃ : និយាយលេង មិននិយាយពីរឿងនយោបាយទេ និយាយលេងពីនេះពីនោះអញ្ចឹងទៅ ណា៎ ។

ប៊ុនថន : ចុះពូកាលជួបគាត់ដំបូងហ្នឹងម៉េចដឹងថាគាត់ប្រធាននៅគុកព្រៃសហ្នឹងពូ?

វ៉ៃ : និយាយមិនដឹងម៉េចបើគេប្រាប់ ។

ប៊ុនថន : អ្នកនៅជាប់ជាមួយពូហ្នឹងពូ?

វ៉ៃ : អត់ទេគេម៉ោមុនៗគេស្គាល់មុន យើងម៉ោក្រោយស្គាល់ក្រោយ ។

ប៊ុនថន :  ពូដឹងតាមរយៈហ្នឹង?

វ៉ៃ :  បាទ!ពីមាត់មួយទៅមាត់ពីរមាត់បីចេះតែស្គាល់តៗគ្នាទៅ ។

ប៊ុនថន :  ចុះពូអត់ដឹងថាគាត់ប្រធាននៅទួលស្លែងទៀតទេ?

វ៉ៃ :  អត់ដឹងទេ ។

ប៊ុនថន :  ទឹមដឹងក្រោយតែពូ?

វ៉ៃ :  បាទ!ដឹងមិនអស់ទេ ព្រោះយើងអត់មានឯកសារផង ទោះអ្នកមានក៏អាចមានភ្លេច ដែរ ។

ប៊ុនថន :  ពូចេញពូព្រៃសហ្នឹងហើយ ពុម៉ោនៅណាវិញពូ?

វ៉ៃ :  ខ្ញុំម៉ោបាត់ដំបងវិញ ។

ប៊ុនថន :  ប៉ុនពូចូលម៉ោខាងកងទ័ពវិញពូ?

វ៉ៃ :  ម៉ោធ្វើប្រជាជននៅស្រុកភូមិ ។

ប៊ុនថន :  នៅភូមិវត្តតាមឹមហ្នឹង ?

វ៉ៃ :  បាទ!នៅភូមិវត្តតាមឹម ឃុំវត្តតាមឹម ក្រោយវត្តខ្វែង ។

ប៊ុនថន :  កាលចាប់ពូទៅហ្នឹងឆ្នាំប៉ុន្មានលោកពូ?

វ៉ៃ :  ចុងហើយហ្នឹង ។

ប៊ុនថន :  ចុង៧៨ឬ៧៧?

វ៉ៃ :  ៧៨ម៉ោវិញយួនចូលស្រុក ម៉ោបានប៉ុន្មានទេ ម៉ោច្រូតៗហើយយួនចូលស្រុកនាំគ្នារត់ម៉ាសារទៀត រត់រផាត់រភើងហ្នឹងគ្រាប់ផ្លោងចូលបាត់ដំបងក៏ឆេះ រត់ទៅតាមផ្លូវលេខ៥ ឆ្ងាយទៅណាទៅបវេលទៅណាព្រៃភ្នំណារទេះគោមួយនឹមហ្នឹងចេះតែបរទៅរខាកៗ ទៅហើយដាក់អង្ករឆ្នាំងទៅវាចង់រស់នោះ អាខ្លះគេអត់រត់ទេនៅ អាអ្នកអត់រត់ហ្នឹងខូច ដាងគេ ហែងរត់អស់អញប្រមូលខ្ទេចខ្ទីអស់ទ្រព្យសម្បត្តិដែលនៅប្រមូលខ្ទេចខ្ទីអស់ អាខ្លះក៏រត់ទៅចោលរបស់ ខ្លះកប់ខ្លះអីទៅ ទៅកាយយករបស់គេទៅអញ្ចឹងទៅមាស ប្រាក់យកទៅកប់ទៅរត់ទៅដៃទទេដល់ម៉ោវិញគេកាយយកអស់ ។

ប៊ុនថន :  អញ្ចឹងលោកពូចង់សួរត្រឡប់ទៅក្រោយវិញបន្តិច ពូពេលបែកខ្មែរក្រហមរំដោះបានឆ្នាំ៧៥ហ្នឹងគេមានបែងចែកកងពូឡើងវិញទេពូ បែងចែករៀបចំជាថ្មីពូ?

វ៉ៃ :  ៧៥គេរៀបចំថ្មីទៅតាមស្រុកទៅតាមតំបន់នីមួយៗ គេរំសាយអង្គភាពចាស់ គេរើសអង្គភាពថ្មីដឹកនាំថ្មីហ្នឹងទៅ ចាស់ហ្នឹងវាទ្រុតទ្រោមទៅ គេរើសអង្គភាពថ្មីដឹកនាំទៅ ។

ប៊ុនថន : បាទ!ពូប្តូរទៅអង្គភាពណាវិញកាលហ្នឹង?

វ៉ៃ : ខ្ញុំកាលហ្នឹងនៅតំបន់ នៅតំបន់៤ ។

ប៊ុនថន : តំបន់៤?

វ៉ៃ : បាទ! នៅជាមួយតាវង់ ៗនៅអន្លង់វិល ៗជិតបាត់ដំបងហ្នឹង ។

ប៊ុនថន : បាទ! តំបន់៤មានស្រុកអីខ្លះពូកាលហ្នឹង?

វ៉ៃ : មានស្រុក៤១ -៤២ ។

ប៊ុនថន : មានស្រុកគេហៅឈ្មោះដូចឥឡូវ?

វ៉ៃ : កាលហ្នឹងគេអានតែលេខទេ ។

ប៊ុនថន : ហៅតែលេខទេ?

វ៉ៃ : ហៅតែលេខដូច៤១-៤២-៤៣អញ្ចឹងទៅ ។

ប៊ុនថន : បច្ចុប្បន្នស្រុកអីវិញពូនៅចាំទេ?

វ៉ៃ : ឥឡូវស្រុកបាត់ដំបងដដែល ខេត្តបាត់ដំបងស្រុកបាត់ដំបង តែឥឡូវហ្នឹងមិនដឹងគេដាក់ស្អីខ្ញុំអត់ដឹងដែរ គេហៅស្រុកអីៗថ្មីនេះខ្ញុំអត់ដឹងព្រោះវាបែកយូរហើយ ។

ប៊ុនថន : អញ្ចឹងពូនៅខាងតំបន់៤?

វ៉ៃ : បាទ!

ប៊ុនថន : ប៉ុនពូនៅខាងផ្នែកយោធា?

វ៉ៃ : បាទ!

ប៊ុនថន : បាទ!ចុះកាលហ្នឹងផ្នែកខាងគណៈតំបន់អីអ្នកណាវិញពូ?

វ៉ៃ : គណៈតំបន់កាលហ្នឹងដូចតាមុត តាភឿន កាលហ្នឹងខ្ញុំ មើល៎!ខ្ញុំចេញពីយោធាម៉ោគេឲ្យខ្ញុំម៉ោខាងធ្វើស្រែ ខាងអាត្រាក់យើងយកពិចិនម៉ោណា៎ ម៉ោធ្វើស្រែយើងនៅនេះផ្ទល់បត់យើងស្វាយអន្លង់កែវនេះ ។

ប៊ុនថន : ស្វាយអន្លង់កែវយើងបាត់ដំបង ពោធិ៍សាត់នេះហ្នឹង?

វ៉ៃ : បាទ!ហ្នឹងហើយម៉ាជួរហ្នឹង កន្លែងស្រែសម្តេចពីដើមហ្នឹង ដល់ព្រោះអីហើយទៅនៅបាត់ដំបង ហើយនៅស្រូវពីណាប្រូគខ្លះទេអត់ដឹងទេ ព្រោះចោលឲ្យគេទៅតាមស្រុកតាមភូមិគេធ្វើទៅ ។

ប៊ុនថន : បាទ!ពូចេញពីហ្នឹងហើយបានទៅនៅតំបន់៤?

វ៉ៃ ៖ នៅតំបន់៤ហើយ ដកយោធាហ្នឹងម៉ោធ្វើស្រែនៅតាមស្រុក ធ្វើហើយឲ្យស្រុកឲ្យភូមិ គេមើលទៅផលមិនផលអីមិនដឹងទេ ដឹងតែម៉ាធ្វើឲ្យគេទេ ។

ប៊ុនថន ៖ បាទ!

វ៉ៃ ៖ ហើយទៅធ្វើឲ្យគេនោះទៀតទៅ ចេះតែដើរធ្វើទៅ ។

ប៊ុនថន ៖ បាទ!ប៊ុនពូនៅខាងយោធាដដែលទេ?

វ៉ៃ ៖ គេដកម៉ោខាងអាគ្រាក់អស់ហើយ លែងមានកាំភ្លើងហើយ ។

ប៊ុនថន ៖ អាហ្នឹងគេហៅអីវិញពូខាងអាគ្រាក់ហ្នឹង?

វ៉ៃ ៖ ធ្វើស្រែកម្មករបង្កើនផល ។

ប៊ុនថន ៖ ចុះពូនៅតំបន់៤មានស្គាល់យាយថែមអីទេ តំបន់៥?

វ៉ៃ ៖ យាយថែម?

ប៊ុនថន ៖ បាទ!យាយថែមខាងព្រះនេត្រព្រះខាងអីពូ?

វ៉ៃ ៖ អត់ទេ!ស្គាល់តែយាយចាន់ ។

ប៊ុនថន ៖ យាយចាន់?

វ៉ៃ ៖ យាយចាន់នៅបាត់ដំបងដែល នៅម្ដុំឈូក យាយចាន់ហ្នឹងកាចណាស់ឃោរឃៅសម្លាប់ គេច្រើនណាស់ ។

ប៊ុនថន ៖ គាត់កាន់ខាងអីវិញ?

វ៉ៃ ៖ កាលហ្នឹងដូចប្រធានឃុំ យាយចាន់ហ្នឹងប្រធានឃុំ ។

ប៊ុនថន ៖ ឈ្មោះគាត់គេហៅតែយាយចាន់ពូ អត់មាននាមត្រកូលអីពូ?

វ៉ៃ ៖ ហ្នឹងហើយហៅតែយាយចាន់ ប្ដីគាត់ឈ្មោះអីទេ ហៅតែចាន់ៗទទេអញ្ចឹង មិនដឹងស្អី ចាន់ៗទេគេហៅតែកំបុតៗអញ្ចឹង ។

ប៊ុនថន ៖ គាត់ប្រធានឃុំ?

វ៉ៃ ៖ បាទ!

ប៊ុនថន ៖ កាលហ្នឹងគាត់ស្រុកនៅណាដែរយាយចាន់ហ្នឹង?

វ៉ៃ ៖ អ្នកនិរតីមិនដឹង ។

ប៊ុនថន ៖ អ្នកតាកែវពូ?

វ៉ៃ ៖ អ្នកតាកែវ ។

ប៊ុនថន ៖ ប្រធានឃុំអីវិញ?

វ៉ៃ ៈ កាលហ្នឹងប្រធានឃុំត្រពាំងក្រោល ។

ប៊ុនថន ៈ ត្រពាំងក្រោលនៅស្រុកអីវិញ?

វ៉ៃ ៈ ត្រពាំងក្រោលកាលហ្នឹងស្រុករាំងសី អីស្រុកអីទេ ។

ប៊ុនថន ៈ រាំងសីដូចមិនមែនស្រុកទេពូ?

វ៉ៃ ៈ រាំងសីកាលហ្នឹងស្រុកមិននៅជាប់ផ្លូវវទេះភ្លើង ឃុំត្រពាំងក្រោល ស្រុកអីគេទេភ្លេចអស់ហើយមិនដឹងមន្ទីរស្រុកគេនៅត្រង់ណាទេកាលហ្នឹង ដូចនៅរាំងសីមិនដឹង ភ្លេចអស់ហើយខ្ញុំដូចយូរពេក ។

ប៊ុនថន ៈ អញ្ចឹងគាត់កាចដែរពូ?

វ៉ៃ ៈ កាចកាប់សម្លាប់គេច្រើនណាស់ ភ្លេចឈ្មោះអស់ហើយយូរពេក ។

ប៊ុនថន ៈ កាលហ្នឹងគាត់ប្រធានឃុំម៉េចមានសិទ្ធនេះអញ្ចឹងពូ?

វ៉ៃ ៈ ទេពីដើមយើងមើលមិនឃើញ មិនបាច់ដល់ប្រធានឃុំ ទឹមឈ្លបប្រធានឈ្លបក៏មានសិទ្ធិសម្លាប់មនុស្សដែរ ដូច្នេះគិតយ៉ាងណានយោបាយគេ ។

ប៊ុនថន ៈ ប៉ុនពូម៉េចបានដឹងថាគាត់កាប់សម្លាប់គេអី?

វ៉ៃ ៈ ចុះយើងនៅជិតហ្នឹងយើងមិនដឹង ដូចអ្នកខុស ខ្ញុំឧទាហរណ៍ថាអ្នកឃ្លានចុះ ទៅកាយតាឡុងស៊ីអីស៊ីទៅវាខុសអីហ្នឹង វាខុសម៉ោពីឃ្លានហើយបើអូសទៅវៃគ្នាចោលធ្វើម៉េចហើយដាំទុកឲ្យអ្នកណាស៊ី បើយើងអ្នកដឹកនាំ ដាំៗឲ្យគ្នាស៊ីបើដាំមិនឲ្យគ្នាស៊ីដាំធ្វើអី ។

ប៊ុនថន ៈ បាទ!អញ្ចឹងយាយចាន់ហ្នឹងនៅរស់ទេសព្វថ្ងៃ?

វ៉ៃ ៈ យី!គេកាប់ចោលតាំងយូរណាស់ហើយ អត់មានរស់ដល់ឥឡូវទេ តាំងយួនចូលស្រុកកាបែលកាប់ចោលបាត់ ចុះបងប្អូនគេនៅរស់សម្លាប់បងប្អូនគេហ្នឹង អាហ្នឹងគេហៅថាទាន់ហន់ ។ មិនបាច់នរកយកទៅទេ តែនរកខ្លួនឯងធ្វើមិនល្អគេអូសយកទៅហើយ ។

ប៊ុនថន ៈ បាទ!លោកពូម៉ោភ្លូរនៅស្វាយដូនកែវនេះរយៈពេលប៉ុន្មាន បានត្រឡប់ទៅវិញ?

វ៉ៃ ៈ ម៉ោព្រោះហើយ ភ្លូររាស់ព្រោះហើយត្រឡប់ទៅវិញធ្វើម៉ាកន្លែងទៀត ។

ប៊ុនថន ៈ ទៅណាវិញពូ?

វ៉ៃ ៈ ទៅស្រុកមោងនោះ ទៅភ្លូរទៅម្តុំផ្លូវទៅដូនព្រៃនោះ ។

ប៊ុនថន ៈ ហើយចេញពីហ្នឹងទៅ ពូទៅណាទៀត?

វ៉ៃ ៈ ចេញពីហ្នឹងទៅដល់ខែស្ទូងហ្នឹងចោលខោអាវ ចាប់អាកង់ដែកនោះវៃអាទាបៗឲ្យប្រជាជនស្ទូងក្នុងកងចល័តគេហ្នឹងៗ យើងវៃទៅឲ្យគេស្ទូងទៅ កងចល័តកងអីគេស្ទូង ទៅ

ហើយស្រូវហ្នឹងបានផលហ្នឹងគេយកទៅណាៗខ្ញុំមិនដឹងទេ ព្រោះយើងអត់បានទៅប្រូតផង ។

ប៊ុនថន : អញ្ចឹងពូដឹកនាំកម្លាំងខាង?

វ៉ៃ : ខាងដើរព្រោះ ។

ប៊ុនថន : បាទ!ខាងអាគ្រាក់ខាងអីហ្នឹង ។

វ៉ៃ : បាទ!

ប៊ុនថន : ពូចេញពីមោងហ្នឹងម៉ោ ពូទៅណាទៀត?

វ៉ៃ : ចេញពីមោងទៅវាមានមន្ទីរគេគ្រឿងចក្រហ្នឹង អស់ការងារគេឲ្យចូលហ្នឹង អាណាខូចយើងធ្វើទៅ ធ្វើបន្ថែមទៅ អាណាបាក់យើងផ្សារវាទៅ នៅអន្លង់វិលអាគ្រាក់ហ្នឹងគ្រឿងចក្រហ្នឹងនៅអន្លង់វិល ។

ប៊ុនថន : ពូនៅហ្នឹងមានរយៈយូរទេពូនៅអន្លង់វិល?

វ៉ៃ : នៅមិនយូរទេ ដូចថាយើងសម្រាកពីការងារ បើមានការងារអីទៀតយើងទៅទៀតមានម៉ោយើងនៅស្ងៀមទេ ម៉ោធ្វើការនោះអត់មានរដូវមានខែអីទេ ។

ប៊ុនថន : ប៉ុនកាលហ្នឹងតាញឹមគាត់ឡើងប្រធានភូមិភាគហើយ?

វ៉ៃ : បាទ!តាញឹមឡើងប្រធានភូមិភាគហើយ រស់ ញឹម ។

ប៊ុនថន : បាទ!ហើយក្រោមគាត់ តាហ៊ុំងអីពូស្គាល់ទេ ?

វ៉ៃ : តាភឹង?

ប៊ុនថន : ឈ្មោះគាត់ហ៊ុំងអីពូ?

វ៉ៃ : ភឹង ។

ប៊ុនថន : ពូស្គាល់ទេពូ?

វ៉ៃ : ខ្ញុំមិនចាំទេដូចថាក្មេច ដូចថាវាចាស់ៗបើនៅឥឡូវក៏ស្លាប់ដែរបើអាយុច្រើនដែរហើយមិនអញ្ចឹងវាក្មេចខ្លះអស់ ដូចថាវាមិនចាប់អារម្មណ៍ថាធ្វើអីទៀត មានតែខំធ្វើស្រែធ្វើចំការមានខំអីណាណីអី នយោបាយអូសទាញឲ្យនេះធ្វើនោះអត់ទេ ធ្វើស្រែធ្វើចំការដាក់ដីថៃដីណាំអីទៅអាហ្នឹងរស់បានយូរ អូសទាញទៅធ្វើណាអ៊ើ!ថាថៃហ្នឹងមានដឹកនាំទៅទប់ទល់ព្រំដែនជាមួយថៃយកនេះយកនោះអញ្ចឹង ដូចថាការងារជាមួយជាតិអញ្ចឹងយើងមិនចាច់ទៅប្រឆាំងទេមិនអញ្ចឹង?

ប៊ុនថន : បាទៗ!

វ៉ៃ : យើងដឹកនាំការពារជាតិ ទំនាស់អីពួកអាអស់ហ្នឹង ពួកអាបរទេសវាចង់យើង ហើយយើងការពាររបស់យើងទៅ ។

ប៊ុនថន : បាទ!ពូនៅអន្លង់វិលហ្នឹងរហូតឬពូទៅប្រចាំការណ៍នៅប៉ៃលិនពូ?

វ៉ៃ : អាហ្នឹងនិយាយផុតហើយអាហ្នឹង អានៅអន្លង់វិលហ្នឹងអាដកសក្ដិដកអីហ្នឹងគេឲ្យទៅនៅប៉ៃលិន នៅប៉ៃលិនហើយគេបង្វិលពីប៉ៃលិនហ្នឹងឲ្យទៅនៅណានោះ ហើយដល់ម៉ោពីនោះម៉ោវិញបានយួនចូលស្រុក ។

ប៊ុនថន : បាទ!

វ៉ៃ : បាទ!អាហ្នឹងវាអញ្ចឹងចប់មាវ៉ាវគ្គហ្នឹង ។

ប៊ុនថន : ទៅនៅប៉ៃលិនវិញហ្នឹងពូនៅកាន់ខាងយោធាវិញ?

វ៉ៃ : នៅខាងយោធា គេឲ្យដកពីអាត្រាក់ហ្នឹងគេឲ្យទៅការពារនៅហ្នឹង ។

ប៊ុនថន : ប៉ុន្តែពូនៅវរៈសេនាធំចាស់ដដែល?

វ៉ៃ : វរៈសេនាធំឈ្មោះអានី មេហ្នឹងឈ្មោះនី នីឡុកវរៈសេនាធំគេហ្នឹង ខ្ទឹម ។

ប៊ុនថន : ខ្ទឹម មានខ្ទឹមទៀត?

វ៉ៃ : មាន ។

ប៊ុនថន : ខ្ទឹមហ្នឹងអ្នកនៅខាងណាវិញពូ?

វ៉ៃ : អ្នកនៅពាយ័ព្យហ្នឹង ។

ប៊ុនថន : អ្នកនៅពាយ័ព្យដែរ?

វ៉ៃ : បាទ!ខ្ទឹមៗ ឈ្មោះ នី ឡុក គ្នាគេហ្នឹង ។

ប៊ុនថន : បាទ!៣នាក់?

វ៉ៃ : បាទ!៣នាក់ អស់ហើយគេចាប់យកអស់ហើយ បើនៅដល់ឥឡូវក៏ចាស់ដែល កាលហ្នឹងចាស់ៗជាងខ្ញុំទៀត ឥឡូវខ្ញុំចំណាស់នេះហើយ ។

ប៊ុនថន : បាទ! អញ្ចឹងពូទៅប្រចាំការណ៍នៅនេះហ្នឹង បានរយៈពេលប៉ុន្មានបានគេចាប់យកម៉ោ ពូ?

វ៉ៃ : ចាប់ទៅនោះឆ្នាំ៧៨ហើយ ព្រោះ៧៩យួនចូលស្រុក ម៉ោវិញប្រហែលបានប៉ុន្មានហើយប្រូតហ្នឹង ។

ប៊ុនថន : ចុះពូកាលគេចាប់គា ញីមអីពូមានដឹងដំណឹងថាគេចាប់ដែរ?

វ៉ៃ : អត់ទេ!អត់មានដឹងថាចាប់ទេ ព្មថាគាញីមក្បត់ៗ ក្បត់មិនដឹងក្បត់រឿងអីយើងអត់ ដឹងដែរ អាហ្នឹងបើគិតទៅការសិក្សារៀនសូត្រ វាដូចខ្ញុំនិយាយអញ្ចឹងវាបានតិចណាស់

ហើយក្នុងសាលាដែលយើងរៀនពីនេះពីនោះហ្នឹង អ្នកណាត្រូវដឹងៗទៅអ្នកអត់ឲ្យដឹងៗយើងដឹងទេ ។

ប៊ុនថន : អញ្ចឹងពូដឹងដែរ ពេលចាប់គាត់?

វ៉ៃ : ចាប់ពីនេះខ្ញុំដឹង គេអូសគាត់ ចាប់ផ្តើមអាក្រោយៗនេះភ័យព្រោះវាខ្សែៗនោះតែចាប់មេអាបន្ទាប់ហ្នឹងទៅហើយ ទៅតាមមុនឬក្រោយទេ ។

ប៊ុនថន : បាទ!អញ្ចឹងចាប់គាត់ហើយ អត់មានចាប់ពីណាផ្សេងៗទៀតទេពូដូចអនុប្រធានអី?

វ៉ៃ : ចាប់ថ្នាក់តំបន់ថ្នាក់អីហ្នឹង ។

ប៊ុនថន : ពីណាខ្លះពូនៅចាំឈ្មោះទេ?

វ៉ៃ : កាលហ្នឹងដូចចាប់តាហ៊ាង តាមុត ហើយនឹងកងទ័ពហ្នឹង កាលនោះរឿងហ្នឹងដូចគេថាសក់អាណាក្បាលអាហ្នឹង គេមិនឲ្យថាពូ ពូៗថាខ្សឹបខ្សៀវចាប់អានេះចាប់អានោះ គេមិនឲ្យយើងផ្អើលទេ ។

ប៊ុនថន : ចុះចាប់កូនគាត់អីពូដឹងទេកូនពូហ៊ាង កូនអី?

វ៉ៃ : អត់!ពូៗឈ្មោះដែរថាគេចាប់ ចាប់ទៅណាៗខ្ញុំមិនដឹង គ្រាន់តែពូរត់ប្រាស់អាយុទៅរត់ទៅក្រៅភូមិបាត់អត់ឲ្យហែងចាប់បានទេ នៅតែភ្លាត់ ហើយម៉ោវិញហ្នឹងបិះៗទៀតរត់គេចតែរហូតហ្នឹង កាលជំនាន់នោះភ័យអរៗ ភ័យរឿងមួយអត់បាយ ពីរផាប់ ។

ប៊ុនថន : បាទ!ចុះពូដែលបានជួបដូចថាមេធំៗ ដូចនួន ជា ដូចអីទេជំនាន់ហ្នឹង?

វ៉ៃ : ជួបទៅប្រជុំអី គាត់នៅរាប់ឆ្នាំនៅជាមួយខ្ញុំនៅសំឡូតហ្នឹង នួន ជា ជាមួយផ្ទះគាត់នៅ ហ្នឹងខ្ញុំនៅហ្នឹង ។

ប៊ុនថន : កាល៧៩ហើយហ្នឹងពូ?

វ៉ៃ : កាលមុនយើងនេះហ្នឹង ។

ប៊ុនថន : មុនរំដោះ៧៥នេះ?

វ៉ៃ : មុនឥឡូវនេះ ។

ប៊ុនថន : បាទ!អញ្ចឹងពូអាចរៀបរាប់បានពេលពូ មុនវៀតណាមចូលម៉ោពូរត់ទៅណា?

វ៉ៃ : ខ្ញុំវៀតណាមចូលម៉ោខ្ញុំរត់ទៅនៅសំឡូត ។

ប៊ុនថន : ម៉ោនៅសំឡូតហ្នង?

វ៉ៃ : បាទ!ជាមួយតាសេនអីហ្នឹង តាសេនអន្លុកភាពផ្សេងទៅ ខ្ញុំអន្លុកភាពផ្សេងទៅ ។

ប៊ុនថន : បាទ!កាលហ្នឹងពូសេន គាត់នៅអន្លុកភាពប៉ុន្មានពូ?

វ៉ៃ ៖ កាលហ្នឹង៦៣ ។

ប៊ុនថន ៖ ៦៣ កាលហ្នឹងគាត់ជាកងវរៈដែលពូ វរៈសេនាតូច?

វ៉ៃ ៖ ទេ!គ្រាន់ប៉ូលីសក្រុមទេកាលហ្នឹង ។

ប៊ុនថន ៖ លោកពូនៅវរៈប៉ុន្មានលោកពូ?

វ៉ៃ ៖ ខ្ញុំនៅ៧១ ។

ប៊ុនថន ៖ ៧១?

វ៉ៃ ៖ បាទ! ៧១ហ្នឹងយូរហើយ តែឥឡូវនៅ៧១មិនដឹងគេចូលគ្នាអស់ទៅ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងគេរៀបចំឡើងវិញពូ ជួបជុំគ្នា?

វ៉ៃ ៖ រៀបចំជាអគ្គភាពវរៈតូច វរៈសេនាធំដោយឡែកៗពីគ្នា ជាក្រុមជាពួកអញ្ចឹងទៅ គេណែនាំយើងថាចេះចុះពេលយើងធ្វើខុសឆ្គងអី ដូចនៅជាមួយម៉ែឪយើងនៅផ្ទះអញ្ចឹងជាក្រុមជាពួក ដូចបងដូចប្អូនដូចម៉ែដូចឪសំខាន់ការនិយាយស្តី យើងណែនាំគ្នាពេលមានខុសអញ្ចឹងទៅ យើងខ្វះសាលារៀនសូត្រទាល់តែមានការណែនាំគ្នាឲ្យបានល្អធ្វើ ម៉េច ។

ប៊ុនថន ៖ បាទ!

វ៉ៃ ៖ រឿងអាយុ ធ្វើម៉េចយើងការពារអាយុជីវិតយើងឲ្យរស់បានយូរអញ្ចឹងទៅណា៎ យើង ធ្វើអីគ្រោះថ្នាក់ធ្វើអីវាគ្រោះថ្នាក់ដល់ជីវិត ។

ប៊ុនថន ៖ ហើយលោកពូនៅនោះខាងផ្នែកពីណា ដូចថាម៉ាផ្នែកខាងហ្នឹងខាងគ្រប់គ្រង?

វ៉ៃ ៖ នៅណា កាលនៅនោះ?

ប៊ុនថន ៖ កាលនៅសំឡូតលោកពូ?

វ៉ៃ ៖ តាម៉េត ។

ប៊ុនថន ៖ ស្វូ ម៉េត?

វ៉ៃ ៖ ម៉ង់ ម៉េត ។

ប៊ុនថន ៖ ឈ្មោះអីវិញពូ?

វ៉ៃ ៖ ម៉ង់ ម៉េត គាត់ប្រធានកងពល ។

ប៊ុនថន ៖ បាទ!កងពលលេខប៉ុន្មានពូកាលហ្នឹង?

វ៉ៃ ៖ កាលហ្នឹងគេហៅតែ០៥៧ ។

ប៊ុនថន ៖ ០៥?

វ៉ៃ ៖ បាទ!ឈ្មោះ០៥ កងពលទី១ ។

ប៊ុនថន : បាទ!ចុះស៊ូ ម៉េតនោះពូ?

វ៉ៃ : ស៊ូ ម៉េតណាទេ មានតែស៊ូ ម៉េតមួយខ្វាក់នោះ ។

ប៊ុនថន : អញ្ចឹងក្រៅពី ម៉ង់ ម៉េត មានពីណាផ្សេងទៀតពូ?

វ៉ៃ : មានតាផល អីផលទេអ្នកស្រុកនៅសំឡូតហ្នឹង ហើយតានឹម ខ្មោចតានឹមហ្នឹងស្លាប់ម៉ាខែពីរខែហើយ នៅប៉ុន្មានហ្នឹងទេ ឥឡូវមានណានៅជាមួយតាភើយហ្នឹង មានតែគង់ តាវិន មានអ្នករិះ ។

ប៊ុនថន : ហើយមេៗមានពីណាពូ ដូចទួន ជាគាត់នៅខាងហ្នឹងដែលពូ នៅបែងខាងពូ?

វ៉ៃ : អ៊ើ!មិនដឹងទៅនៅណាទេ តាំងពីយួនចូលស្រុក នៅណានៅណីទេខ្ញុំមិនសូវបានដើរ ផង ។

ប៊ុនថន : បាទ!ចុះតាម៉ុកៗគាត់នៅខាងណាពូ?

វ៉ៃ : តាម៉ុកឥឡូវមិនដឹងគាត់នៅណាអត់ដឹង ។

ប៊ុនថន : អត់ទេ! និយាយកាលជំនាន់ពូ?

វ៉ៃ : អ្ហូ! គាត់នៅអន្លង់វែងនេះ ។

ប៊ុនថន : បាទ!គាត់អត់នៅខាងប៉ែកពូទេ?

វ៉ៃ : អត់ទេ! នៅខាងអន្លង់វែង ទួន ជានៅខាងនេះនៅខាងសំឡូត ។

ប៊ុនថន : ខាងសំឡូតនៅខាងជាមួយពូវិញ?

វ៉ៃ : បើតាម៉ុក នៅខាងអន្លង់វែងនោះ ។

ប៊ុនថន : ហើយ សុន សេនអីគាត់នៅខាងសំពៅលូននោះ?

វ៉ៃ : បាទ!នៅបណ្ដាក់គ្នាដូចខ្សែអញ្ចឹង ហើយពុទាស់ទែងគ្នាគាៗ ម៉េចខ្ញុំមិនដឹងទេ អ្នកណាសម្លាប់អ្នកណា អ្នកណាអីណាលែងដឹងលែងពុហើយ ។

ប៊ុនថន : បាទ!ចុះពូនៅនេះដូចតំបន់សំឡូតហ្នឹងចាប់ពីណាដល់ណាពូ?

វ៉ៃ : សំឡូតយើងតំបន់ចាប់ពីថ្នល់ជាតិលេខ១០ម៉ោនេះ ម៉ោដល់នេះមុំអ្ហូសិរិលមុំយើងហ្នឹង កំពង់ទោលអីហ្នឹងខាងសំឡូតហើយហ្នឹង ។

ប៊ុនថន : បាទ!ចុះខាងនេះ ប៉ែកខាងវាល វែង?

វ៉ៃ : វាល វែងហ្នឹងពីដើមគេហៅច្រក៥០៥ ។

ប៊ុនថន : ៥០៥?

វ៉ៃ : បាទ!ម៉ោខាងថ្មដាអីហ្នឹងគេហៅច្រក៥០៥ ។

ប៊ុនថន : បាទ!ខាងហ្នឹងពីណាគេគ្រប់គ្រងពូ តាម៉ុត?

វ៉ៃ ៖ មាស មុំត ។

ប៊ុនថន ៖ អញ្ចឹងពូដាច់ដោយឡែកទៅខាងនោះ ហើយមុំតគាត់ម៉ោខាងនេះ?

វ៉ៃ ៖ បាទ!កាលនៅសំឡូតខាងនោះមានតាម៉េតហ្នឹង ម៉ង់ ម៉េតហ្នឹង ហើយម៉ោខាងនេះមាន មាស មុំត ។

ប៊ុនថន ៖ បាទ!៥០៥?

វ៉ៃ ៖ បាទ!៥០៥ ។

ប៊ុនថន ៖ អញ្ចឹងនៅខាងនោះរហូតមានប្តូរទៅណាទេពូ?

វ៉ៃ ៖ ម៉ោពីសំឡូតខ្ញុំនៅម៉ោនៅហ្នឹង ។

ប៊ុនថន ៖ បាទ!កាលហ្នឹងមានប្រជុំមានអីទេពូ ឡើងទៅប្រជុំជាមួយមេធំៗអញ្ចឹង?

វ៉ៃ ៖ មាន ប៊ុនទួន ជា ប៊ុនអីហ្នឹងគេហៅយកទៅប្រជុំ ។

ប៊ុនថន ៖ ប្រជុំនៅណាវិញពូ?

វ៉ៃ ៖ ប្រជុំគេធ្វើសាលាមួយ នៅកណ្តាលព្រៃទៅ ។

ប៊ុនថន ៖ អ្ហូ!គាត់ចុះម៉ោប្រជុំ ឬក៏មេៗទៅប្រជុំត្បាកន្លែងហ្នឹង?

វ៉ៃ ៖ ទៅគេដើរទៅកន្លែងសាលាមន្ទីរហ្នឹងទៅ ២ថ្ងៃ៣ថ្ងៃបើថាសភាពការណ៍ទៅវាយូរទៅ សភាពការមិនសូវល្អ២ថ្ងៃ៣ថ្ងៃទៅណា៎ ។

ប៊ុនថន ៖ ក្រៅពីគាត់មានពីណាទៀតពូ មេៗ?

វ៉ៃ ៖ ម៉ាចន្លោះហ្នឹងឃើញតែតាហ្នឹងមួយ តាទួន ។

ប៊ុនថន ៖ បាទ!ប៉ុល ពតអីគាត់អត់ដែលចុះម៉ោទេ?

វ៉ៃ ៖ អត់ទេ!

ប៊ុនថន ៖ សុន សេន អៀង សារីអីអត់ដែរ?

វ៉ៃ ៖ អត់!ឃើញម៉ោ នៅតាមផ្នែកនៅម៉ាច្រកៗម៉ាផ្នែកៗ ។

ប៊ុនថន ៖ បាទ! ហើយពូមានទៅណាទៀតទេនៅសំឡូតហ្នឹង?

វ៉ៃ ៖ អត់ទេម៉ោពីសំឡូតម៉ោនេះម៉ង ម៉ោនៅហ្នឹង ។

ប៊ុនថន ៖ ម៉ោនៅហ្នឹងឆ្នាំប៉ុន្មានពូ?

វ៉ៃ ៖ អេ៎!ម៉ោនេះយូរដែលហើយម៉ោតាំងពី អេ៎!យូរដែលហើយម៉ោតាំងពីជំនាន់យើង ប៉ៃ លិនចូលរដ្ឋាភិបាលនោះ ។

ប៊ុនថន ៖ បាទ!៩៦ពូ?

វ៉ៃ ៖ បាទ!ហ្នឹងហើយម៉ោពេលហ្នឹង ឆ្នាំហ្នឹង រង្គោះរង្គើលគ្នាគេឲ្យម៉ោខាងនេះម៉ោ ។

ប៊ុនថន ៖ ៩៦ហ្នឹងនៅជាប់ហ្នឹងរហូតឬក៏ពូមានទៅណាទៀតពូ?

វ៉ៃ ៖ អត់ទៅណាទៀតទេខ្ញុំនៅជាប់រហូត ។

ប៊ុនថន ៖ ចុះមានថាវ៉ៃគ្នាជាមួយទាហានខាងក្នុងពូ មុនហ្នឹងទៀតពូ?

វ៉ៃ ៖ កាលមុនវ៉ៃ កាលយើងមិនទាន់ត្រូវគ្នាអាក្រោយនេះ វ៉ៃតាមផ្លូវយើងនេះផ្លូវ៥៦ហ្នឹង ហើយវ៉ៃម៉ុំយើងកោះប៉ោត ដងទង់អីទៅស្រែអំបិល ទៅថ្មបាំងអញ្ចឹង ។

ប៊ុនថន ៖ ប៉ុនមានដែលវ៉ៃចូលដល់ហ្នឹងទេពូ ខាងក្នុង?

វ៉ៃ ៖ ចូល ។

ប៊ុនថន ៖ ចុះពូដកទៅណាវិញ?

វ៉ៃ ៖ ខ្ញុំនៅតែហឹងក្នុងភូមិហ្នឹង អត់ទៅណាទេ ហើយគេម៉ោពីនោះក៏គេម៉ោមិនយូរដែរ ម៉ោម៉ាឆាវគេទៅវិញអស់ គេសេដ្ឋកិច្ចពេញថ្នល់មិនមានឡានដឹកណា ហើយម៉ោពីនោះម៉ោដល់នេះ ទំរាំមកដល់នេះក៏យ៉ាប់ដែរ អស់ដៃអស់ជើង ហើយកុំថាយើងនៅនេះអត់ហត់អត់អី ងាប់គរមិនតិចណាទៅវិញអស់ រស់តែ១-២សែងទៅវិញអស់ ។

ប៊ុនថន ៖ លោកពូម៉ោនេះម៉ោទាំងកងវរៈពូម៉ោម៉ង់ ឬទេ?

វ៉ៃ ៖ បាទ!ម៉ោម៉ាកងវរៈម៉ង ។

ប៊ុនថន ៖ ចុះម៉ោនេះគេបែងចែកគ្រប់គ្រងម៉េចទៅលោកពូ ដូចថាខាងនោះមានម៉ង់ ម៉េតអញ្ចឹង ម៉ោនេះខាងមាស ម៉ុត?

វ៉ៃ ៖ ម៉ោនេះគ្រប់គ្រងផ្នែកតែមួយ ដឹកនាំតែមួយគ្មានអីទេ?

ប៊ុនថន ៖ ខាងណា ពីណាអ្នកដឹកនាំពូ?

វ៉ៃ ៖ អ្នកដឹកនាំមាន អៀង ដាន ។

ប៊ុនថន ៖ អៀង ដាន?

វ៉ៃ ៖ បាទ!

ប៊ុនថន ៖ អៀង ដានគាត់ធ្វើអីដែរសព្វថ្ងៃពូ?

វ៉ៃ ៖ អេ៎!អៀង ដានដូចគាត់ធ្វើការនៅភូមិភាគ៥ ។

ប៊ុនថន ៖ ភូមិភាគ៥ ?

វ៉ៃ ៖ នៅជាមួយប៊ុន សេងគាត់អ្នកគ្រងគ្រង ។

ប៊ុនថន ៖ បាទ!អញ្ចឹងតំបន់វាលវែងហ្នឹងគាត់អ្នកគ្រប់គ្រងវិញ?

វ៉ៃ ៖ បាទ!

ប៊ុនថន ៖ ចុះមាស ម៉ុតនោះគាត់អត់គ្រប់គ្រងទេ?

វ៉ៃ ៖ មាស ម៉ុតគាត់ប្រធានច្រកប្រធានការគ្រប់គ្រង ច្រកហ្នឹងមានតែគាត់ហ្នឹងឋានៈខ្ពស់ ដាងគេ បន្ទាប់មកមានអៀង ដាន ។

ប៊ុនថន ៖ អៀង ដានគាត់ជាអ្នកបញ្ជាការផ្ទាល់?

វ៉ៃ ៖ បាទ!អៀង ដានអ្នកបញ្ជាផ្ទាល់ បន្ទាប់មកក្រោមៗភ្លេចអស់ហើយ រាយការណ៍មាំ យប់វាមិនអស់ទេ រឿងវាមាំគន្ទាក់ៗពិបាកនិយាយ វាអត់មានសាច់រឿងខ្សែវា ដូច គេតែងចាក់កាសែ្សតឲ្យយើងមើល មិនអញ្ចឹង?

ប៊ុនថន ៖ បាទ!

វ៉ៃ ៖ ហើយយើងយកមកនិយាយអញ្ចឹងម៉េចដូចគេលេង ។

ប៊ុនថន ៖ បាទ!ហើយនៅនេះក្រោយពីសមាហរណកម្មហើយយ៉ាងម៉េចពូ រៀបចំប្រជាជន កង ទ័ពអីយ៉ាងម៉េចដែរលោកពូ?

វ៉ៃ ៖ ប្រជាជនរៀបចំជាភូមិ ជាប្លង់ដីទៅចែកទៅ ម្នាក់មាំប្លង់ទៅបានប៉ុន្មានបានទៅតាម គ្រួសារតិចគ្រួសារច្រើនអញ្ចឹង ហើយកងទ័ពនោះវាមានអត្តភាពគេដោយឡែកទៅការ គ្រប់គ្រងរបស់ផ្សេងទៅ ភូមិគេគ្រប់គ្រងភូមិទៅ ឃុំគេគ្រប់គ្រងឃុំទៅ ។

ប៊ុនថន ៖ ហើយមានរបបទេលោកពូ?

វ៉ៃ ៖ អត់!

ប៊ុនថន ៖ អត់មានរបបទេអញ្ចឹងគាត់ធ្វើចំការធ្វើអីទៅ?

វ៉ៃ ៖ បាទ!ធ្វើចំការទៅ ។

ប៊ុនថន ៖ បាត!ហើយបែងចែកស្រុកហ្នឹងគេបែងចែកតាំងពីណាពូស្រុកវាលវែង?

វ៉ៃ ៖ ស្រុកវាលវែងគេបែងចែក(ស្តាប់មិនបាន ដោយសម្លេងរន្ទះ) ។

ប៊ុនថន ៖ សមាហរណកម្មហើយបានគេបែងចែកលោកពូ?

វ៉ៃ ៖ បាទ! គេសួរយើងហើយបានគេរៀបភូមិ រៀបតំបន់ហើយបានរៀបឃុំរៀបស្រុក អញ្ចឹងចូលក្នុងខេត្តពោធិ៍សាត់អញ្ចឹង ។

ប៊ុនថន ៖ កាលមុនគេហៅអីវិញតំបន់ហ្នឹង?

វ៉ៃ ៖ តំបន់ហ្នឹងគេហៅតំបន់ ឃុំគេហៅឃុំប្រមោយ ។

ប៊ុនថន ៖ ប៉ុននៅក្នុងខេត្តណាវិញពូ?

វ៉ៃ ៖ ខេត្តពោធិ៍សាត់ដែរ ។

ប៊ុនថន ៖ ក្រោយសមាហរណកម្មហើយបានគេបែងទៅជាស្រុកវាលវែង?

វ៉ៃ ៖ បាទ!

ប៊ុនថន ៖ លោកពូខ្ញុំចង់សួរពូមួយទៀតពេលមុនសមហរណកម្មនឹងក្រោយសមាហរណកម្មពូដូចថា មានប្លែកយ៉ាងម៉េចដែរ ប្លែកការរស់នៅប្លែកជីវភាពអញ្ចឹង?

វ៉ៃ ៖ ប្លែកបន្តិចម្ដងៗវារីករាយហើយវាដូចថា លូតលាស់ទៅមុខតាមសង្គមតាមការដឹកនាំ តាមការរៀនសូត្រចេះយល់បានច្រើន កាលមុនយើងអត់ទាន់យល់ ។

ប៊ុនថន ៖ ហើយឃ្លាចង់ក្រោយចង់សួរពូដូចថា សព្វថ្ងៃនេះយើងមានដូចថាតុលាការកាត់ទោស មេដឹកនាំខ្មែរក្រហមមានដូចជា នួន ជា អៀង សារី ខៀវ សំផន ហើយអៀង ធីរិទ្ធ ហើយលោកពូយល់យ៉ាងម៉េចដែរលោកពូ?

វ៉ៃ ៖ អត់អីទេខ្ញុំ អាហ្នឹងជារឿងរបស់ខាងលើ នយោបាយគេ គេកាត់ទោសយ៉ាងម៉េច កុំឲ្យ តែរាលដាលដល់ប្រជាជនដូចថាសង្កាត់ណាកាត់សង្កាត់ហ្នឹងទៅ?

ដានី ៖ ពូយល់ថាត្រឹមត្រូវដែរឬក៏មិនត្រឹមត្រូវទេបើតាមចិត្តរបស់ពូផ្ទាល់?

វ៉ៃ ៖ ការធ្វើហ្នឹងបើមិនត្រឹមត្រូវគេអត់ធ្វើទេ មិនអញ្ចឹង បើត្រឹមត្រូវបានគេធ្វើ មិនត្រឹម ត្រូវធ្វើទៅវាទំនាស់ ។

ដានី ៖ អត់ទេ!ពួកខ្ញុំសួរនេះសួរចង់ដឹងពីតាមយោបល់ពូ ពីការយល់ឃើញរបស់ពូ ការ បង្កើតការកាត់ទោសហ្នឹងមានករណី០០១ ០០២ម៉ោហ្នឹង បើតាមយោបល់ពូតាម ការគិតរបស់ពូ ពូគិតថាវាត្រឹមត្រូវដែរឬយ៉ាងម៉េច?

វ៉ៃ ៖ ក្នុងមតិខ្ញុំការកាត់ទោសមេទាំងប៉ុន្មាននាក់ហ្នឹង មានច្បាប់អីត្រឹមត្រូវទៅគេដុំម៉ោ ចង ក្រងជាទោសកំរិតណាអីកំរិតណា តំកល់នៅក្នុងក្រសួងកន្លែងសភាគេខ្វះទៅ មានអី គេគ្រាន់ផ្សព្វផ្សាយ ទី១យើងគិតជាតិអ្នកដឹកនាំដែលរីកចំរើន ទី២យើងគិតពីម្ដាយឪ ពុកយើងចាស់ៗយើងធ្វើម៉េចចិញ្ចឹមគាត់ឲ្យបានអាយុវែង ទី៣យើងខ្លួនឯង ។

ប៊ុនថន ៖ បាទ!ចុះលោកពូមានអីចង់បន្ថែមទៀតទេ?

វ៉ៃ ៖ អត់មានអីទេ មានតែការថ្លែងប៉ុនហ្នឹង ហើយយើងនិយាយយកទៅចងក្រងជាឯកសារ ក៏វាពិបាកដែរវាអត់មានឯកសារអីអាន និយាយនេះម៉ាចុបនោះម៉ាចុបវាពិបាក ។

ប៊ុនថន ៖ អញ្ចឹងខ្ញុំអរគុណលោកពូច្រើន លោកពូ ។

វ៉ៃ ៖ បាទៗ! ។

ចប់